«ខ្ញុំនៅខាងក្រោមនេះ! រកវិធីយកខ្ញុំចេញទៅ! លឿនឡើង!»

សូរមនុស្សស្រីយំលាន់មកទ្រហឹង។ ចេញមកជិតឈុនរាជពីមុខក្រោយឆ្វេងស្ដាំដំណាលគ្នា។

សំឡេងពួកគេខ្សាវៗទំនងជាត្រូវបង្អត់អាហារ។

«អាចោលម្សៀតណាមួយបានចាប់ពួកនាងទាំង៥មកទុកដោយឡែកពីគ្នា ហើយនៅទីនេះទាំងអស់បានជានាងមិនអាចវិលទៅផ្ទះ ហើយប៉ូលិសរកមិនឃើញដាន?»

គេកំពុងឆ្ងួតវង្វេងនឹងសេចក្ដីស្រមៃទុកក្នុងការបានឡើងលើក្របមុខកាសែតនានា ពីស្នាដៃរំដោះចំណាប់ខ្មាំងជាស្រីស្អាតកូនអ្នកមានទាំង៥រូប។

ដៃគេរាវដល់ប្រភពពន្លឺ ហើយចុងក្រោយ គេរកឃើញរនុកធំមួយសែនតឹង។ តែទោះតឹងយ៉ាងណាក៏គេមានសង្ឃឹមដែរព្រោះថា...

«អស្ចារ្យណាស់! វាគ្មានចាក់សោទេ!»

គេនិយាយខ្សឹបប្រាប់អ្នកខាងក្រោមដោយអំណរ។

«តែប្រហែលជាខាងក្រោមជ្រៅហើយបានជាពួកនោះមិនគិតចាក់សោពីក្រៅ?»

គេគិតដូច្នេះវិញទាំងដៃប្រឹងអស់ពីសមត្ថភាពក្នុងការមួលបើករនុក។

«ឆ្ងួតណាស់ អាឆ្ងួតអើយ!»

គេនិយាយទាំងក្ដៅចិត្ត ព្រោះរនុកមិនងាយបើកបានសោះ វាតឹងមហាតឹង ថែមទាំងធ្ងន់ទៀត។

គេងាកសម្លឹងជុំវិញខ្លួន... នេះជាជញ្ជាំងភ្នំក្រាស់ណាស់។

«អ្នកណានៅពីក្រោយការបង្ខាំងមនុស្សដូចសត្វនេះ?»

នាយសួរខ្លួនឯងទាំងចិត្តខ្លោចផ្សារ។

ឈុនរាជក្រឡេកសន្សឹមៗ សម្លឹងមើលទៅក្នុងរូងខាងក្រោមរនុកដ៏ធំដែលចកមិនចេះរបើក។

ច្បាស់លាស់ គេឃើញស្រីម្នាក់កំពុងឈរហើយកាន់អ្វីមួយដូចជាទូរសព្ទ។

ការងងឹតលែងមានហើយ តែកម្លាំងដ៏មានព្រំដែនរបស់ខ្លួនឯងកំពុងធ្វើឱ្យគេមានការខកចិត្តយ៉ាងសម្បើម។

«នាងកាន់ទូរសព្ទមែនអត់? ម៉េចមិនឆាប់ខលរកជំនួយ?»

«គ្មានសេវាទេ!»

នាងឆ្លើយធ្វើឲ្យនាយដឹងថា នាងពិតជាមានទូរសព្ទមកតាម។

«គិតម៉េចទៅ ខ្ញុំបើករនុកមិនបានសោះ! បើកមិនរួច!»

«ខំម្តងទៀតទៅ! ខ្ញុំដឹងថា លោកមានវិធី! សាកល្បងឲ្យអស់ទៅ! មិនបាច់បង្ខំទេ! គ្មានអ្នកណាគេមកទាន់ទាំងអស់! ពួកវាមិនមកទេ!»

ពួកនាងជាប់នៅក្រោមនេះ តែដឹងស្ថានការណ៍ខាងក្រៅច្បាស់ណាស់? ថាមិនបាននារីកម្សត់ទាំងនេះ បាននិយាយរកគ្នាជារឿយៗផងក៏មិនដឹង ព្រោះពួកនាងអាចបញ្ចេញសំឡេងបាន។

គេគិតហើយ ក៏និយាយឡើងទាំងអំណរះ

«នឹកឃើញហើយ! ក្នុងចំណោមរនុកទាំង៥ច្បាស់ជាមានមួយណាមិនសូវមាំ បើបានដៃថែមម្នាក់

ទៀតមកជួយ យើងអាចសង្ឃឹមច្រើន!»

គេចាប់ផ្តើមស្វែងរកទីតាំងផ្សេងដោយប្រើជើងស្ទាប។

គេពិតជាបានឃើញទ្វារទីពីរហើយមានរនុកដូចគ្នាមែន។ ទោះយ៉ាងណានាយនៅតែរំកិលវាមិនបានច្រើនទេ។ ទ្វារមិនរបើករួចឡើយ។

«ម៉េចក៏មិនចេញទៅរកគេមកជួយមក!»

សំឡេងស្រីម្នាក់សួរមកទាំងយំផង។

អ្នកផ្សេងជំទាស់៖

«អត់ទេ! បើគាត់ទៅបាត់លែងមកវិញ ពួកយើងសង្ឃឹមអី?»

ព្ទហើយ ឈុនរាជនឹកហេងហាងក្នុងចិត្តម្នាក់ឯងដូចកំពុងស្ថិតលើទូកកណ្ដាលទន្លេដៃទាំងគូគ្មានច្រវ៉ា។

«បើខ្ញុំឲ្យពួកនាងដឹងថា ខ្លួនខ្ញុំក៏មិនស្គាល់ទីតាំងម្ដុំនេះ តើបន្ថែមក្ដីអស់សង្ឃឹមដល់ខ្ញុំកម្រិតណា?»

ដោយគ្មានការព្រាងទុក គេបានថយទៅប៉ះនឹងរនុកមួយថ្មីទាំងមិនបានដឹងផងថា វាភ្ជាប់ជាមួយបន្ទះដែកដែលជាច្រកចូល។ រនុកនេះ ពិតជាស្រួលទាញបំផុតបើធៀបនឹងទីកន្លែងដែលស្រីម្នាក់កំពុងបញ្ឆាំងភ្លើងឡើងមក គឺវាខុសគ្នាទ្វេគុណ។

សោរបើកចិត្តគេដូចបានហោះហើរដល់ផ្ទះវិញ។

គេប្រញាប់បើកបន្ទះដែកដែលងងឹតស្លុបគ្មានមើលអ្វីឃើញទាំងអស់។ ក្លិនឆ្អេះឆ្អាបជះចេញមកពីខាងក្នុងធ្វើឲ្យប្រធាននិស្សិតសឹងត្រូវដាច់ផ្ងារ។

គេប្រញាប់ប្រញាល់ស្រែកសួរទៅខាងក្រោម៖

«មើលមកខ្ញុំឃើញអត់? ខ្ញុំមើលទៅមិនឃើញទេ ងងឹតណាស់! ខាងក្រោមមានជណ្ដើរទេ? មានអ្វីឡើងមកបានដែរអត់?»

សំឡេងខ្លួនឯងលាន់ខ្ទរមកវិញ។ មិនគួរឲ្យជឿបន្តិចណាទេ ដែលថាពួកនាងអាចនៅក្នុងនេះបានមួយសប្ដាហ៍។

ជើងរបស់ប្រធាននិស្សិត ញ័រជាមួយនឹងភាពភ័យខ្លាចថា ប្រសិនគេខ្លួនឯងជាអ្នកដែលត្រូវនៅក្នុងទ្រុងងងឹតនេះ?

«បងមានអីវែងៗក៏ដោយ បោះចុះមក ឲ្យខ្ញុំតោងឡើងទៅផង!»

នារីនោះខំនិយាយទាំងខ្សាវៗធ្វើឱ្យអារម្មណ៍ប្រធាននិស្សិតត្រលប់មកផ្ដុំនៅជុំវិញមាត់អណ្ដូងមានទ្វារនេះវិញ។

«អូខេ!»

គេឆ្លើយផង រួសរាន់ដោះខ្សែក្រវ៉ាត់ហើយទម្លាក់សំយុងទៅក្រោម។ សេចក្ដីអស់សង្ឃឹមខ្ទាត់ខ្ទាយអស់បាត់ ព្រោះពិតជាមានមនុស្សទាញរំញ័រក្បាលខ្សែ។

ប្រធាននិស្សិតដឹងថា ខ្លួនត្រូវធ្វើអ្វីហើយពេលនេះ។

គេច្បាមម្រាមជើងទាំងដប់ ប្រឹងទប់ជំហរប្រទាញនាងឡើងមក។ ឈុនរាជខ្លួនឯងក៏មិនដែលធ្លាប់គិតថាខ្លួនឯងខ្លាំងដល់ថ្នាក់នេះទេ ឬមួយនាងអត់ចំណីស្គមពេក? ឬមួយក្នុងកាលៈទេសៈចាំបាច់មនុស្សយើងលែងទម្រន់ លែងលាក់កម្លាំង?

នារីនោះខ្ទាតមកក្រៅដោយការទាញរបស់នាយ រួមជាសម្រែកដ៏អំណររបស់នាងផង៖

«ខ្ញុំឡើងបានហើយ!»

តើនាងធ្លាប់ព្យាយាមឡើងមកប៉ុន្មានដងហើយ? គេឈរធ្មឹងគិតទាំងស្រឡាំងកាំង។

គ្មានអ្នកណាមានចម្លើយទេ ព្រោះពេលនេះនារីរងគ្រោះស្ទុះទៅទិសខាងឆ្វេងគឺទិសដែលមានពន្លឺ។ សំឡេងនាងនិយាយប្រញាយប្រញាប់៖

«តោះ! ជួយបង Rose ចេញមក គាត់មានពិល និងមានទូរសព្ទ!»

អ្នកទោសស្អាតៗទាំងនេះពិតជាបានជជែកគ្នា ស្គាល់គ្នាមុនពិតណាស់។ ឈុនរាជគិតហើយរត់ទៅតាមពីក្រោយនារីនោះ ផ្ទុកសួរខ្លួនឯងនូវសំណួរជាច្រើន៖

«ពួកអាអ្នកដែលចាប់នាងមក តាមពិតវាមិនបានបង្អត់នាងទេឬអ្វីបានជានាងមានកម្លាំងរត់លឿនម្ល៉េះ?»

នាងមិនត្រឹមតែរត់លឿនទេ កម្លាំងដករនុកក៏ខ្លាំង។

បន្ទះដែកពីលើរូងរបស់ Rose របើកប៉ើងឈុនរាជអុកគូទទឹសហើយនាំមកជាមួយនូវពន្លឺពិលក្រហមច្រាល។ ទីនេះងងឹតស្លុប ដូច្នេះពន្លឺតិចតួចក៏អាចធ្វើឲ្យគ្រប់យ៉ាងក្លាយជាចិញ្ចែងចិញ្ចាចដែរ កុំថាឡើយពន្លឺពិល Laser នេះទៀត។

ជាមួយសេចក្តីសង្ឃឹមដែលរីកធំឡើងៗ គេខំដាក់ខ្សែក្រវាត់ចុះទៅ តែភ្នែកពិនិត្យជុំវិញតំបន់ដែលគេឃុំមេពិធីការរបស់មហាវីន។

នាងទើបមកដល់គុកនេះក្រោយគេប៉ុន្មានម៉ោងប៉ុណ្ណោះបានជារូងនាងហាក់គ្មានក្លិនកខ្វក់ដូចនារីទីមួយ។

Rose ឡើងមកបានយ៉ាងរហ័ស ហើយដៃនាងដែលក្តាប់ពិលជាប់រវៀសរវែររកចំណុចរនុកផ្សេងៗជាមួយវាចាប្រាប់លាន់រំពង៖

«ពួកយើង! ត្រៀម! យើងនឹងចេញពីកន្លែងនរកនេះទាន់ពេល!»

នារីទាំងពីរជួយគ្នាដករនុកបន្តបន្ទាប់ ចំណែកឈុនរាជនៅឈរវត្តុបភាំងស្មារតីចំពោះហេតុការណ៍នៅនឹងមុខខ្លួន។

«ទីបំផុតយើងជាអ្នកទីមួយដែលរកឃើញកូនស្រីអ្នកមានបាត់ខ្លួនកក្រើកក្រុងទាំង៥នាក់នេះ? ហើយចុះបើពេលនេះលោតែពួកវាមកទាន់? ពួកវាណា? ហេតុអ្វីវាចាប់ស្រីៗក្មេងៗអស់នេះមកឃុំទុកដូចសត្វធាតុ? ដើម្បីអ្វីទៅ? ទីនេះសង់មករបៀបណាកើត? ម្តេចក៏គ្មានអាជ្ញាធរណាដឹង?

ហើយអ្នកដែលនៅពីក្រោយរឿងអស់ទាំងនោះជាអ្នកណា? »

បរិយាកាសនៅជុំវិញ កាន់តែស្ងប់ស្ងាត់សេចក្តីបារម្ភចេះតែកើនឡើង។

«កុំបន្លាយពេល ឆាប់ឡើង! យើងនាំគ្នាចេញពីកន្លែងនេះ!»

គេថាហើយ រត់ទៅក្បែរពួកនាងដោយជួយប្រទាញពួកអ្នកទោសឡើងមកជាបន្តបន្ទាប់រហូតគ្រប់គ្រប់៥នាក់។ នារីចុងក្រោយគេឡើងមកឈរចំចំណុចកណ្តាល ហើយឈុនរាជមើលឃើញនាងកាលណាកើតក្តីភ្ញាក់ផ្អើល។

នាងមានទម្រង់មុខតូចច្រឡឹងគួរឲ្យស្រលាញ់ ដូចជាធ្លាប់ឃើញថតជាមួយឪពុកម្តាយជាអ្នកមានរបស់នាងនៅឯណាតែរកនឹកមិនឃើញ។ ដឹងតែថានាងមកពីសង្គមជាន់ខ្ពស់ហើយឪពុកម្តាយជាមនុស្សល្បីឈ្មោះ។

«យើងចេញរកកន្លែងមានសេវា!»

សំឡេង Rose ប្រៀបបីដូចជាមេដឹកនាំដែលនាំមកនូវភាពអង់អាចរឹងមាំឲ្យដល់ពួកនារីៗជាអ្នកទោសអស់ទាំងនេះ។

ពួកគេបោះជំហានតាមពីក្រោយពន្លឺពិលរបស់នាង ហើយឆ្ពោះទៅកាន់ជណ្តើរ ប៉ុន្តែឈុនរាជប្រជ្រៀតទៅមុនដើម្បីបញ្ចប់ភាពឆ្ងើងឆ្ងល់ខ្លួនឯង។

គេប្រឹងដើរឲ្យបានលឿនៗតាមនារីខ្ពស់ស្រលះម្នាក់នោះផង មាត់សួរខ្សឹបៗផង៖

«ម៉េចក៏ពួកវាព្រមឲ្យនាងយកពិលចូលមក!»

និយាយចប់គេក៏ដឹងខ្លួនដែរថា នេះជាសំណួរដ៏លេលា ព្រោះគ្មានពួកឧក្រិដ្ឋជនឯណាយល់ព្រមទេ។ នារីនេះមានវិធីលាក់យករបស់នេះចូលមកបានខ្លួនឯងពិតណាស់។ គេតាមសម្លឹងដៃនាងដែលរេបញ្ចាំងចុះឡើងយ៉ាងរហ័ស។ វាជាប្រភេទពិលដ៏តូចស្មើនឹងមួយម្រាមដៃមនុស្សឬថែម៥០ភាគរយទៀតតែប៉ុណ្ណោះ។

គេងើបភ្នែកម្ដងទៀតទៅកាន់ស្ត្រីមេពិធីការហើយសរសើរ៖

«គ្រាន់បើណាស់ចេះមានរបស់ពិសេសនេះមកតាមបាន កុំអីគ្មានអ្នកណាចេញរួចទេ បងឈុនរាជនេះក៏អត់ស្គាល់ទិសតំបន់ដែរ!»

ជំហានដែលនាងដើរចុះជណ្ដើរហាក់ញាប់ឡើងលើសមុនទ្វេដង តែមាត់នាងក៏មិនបានបដិសេធថាមិនឆ្លើយនឹងនាយដែរ។ Rose ឆ្លើយតបខ្សាវៗ៖

«ស្នងការ Roy ឲ្យវាមកខ្ញុំ! ចុងក្រោយខ្ញុំរស់បានដោយសាររបស់នេះ!»

នាងមានទឹកមុខដ៏រឹងមាំនិងកែវភ្នែកដែលពិចារណាជ្រាលជ្រៅ ល្មមឲ្យក្មេងស្រី៤នាក់ផ្សេងទៀតជឿជាក់រត់មកតាមត្រុកៗ។

អុកស៊ីហ្សែននៅខាងក្រៅ ពិតជាជាប្រសើរជាងខាងក្នុងខ្លាំង បានជាឈុនរាជឃើញអ្នកទោសស្រីទាំងបួនហ៊ោកញ្ញើវពេលចេញមកប៉ះកម្លាំងខ្យល់។ សរសៃសក់ពណ៌ខ្មៅក្រឹបៗវែងៗដែលបក់រវិចនៅលើស្មាពួកគេ បានឡោមព័ទ្ធឲ្យលេចអណ្ដែត មកនូវគ្រឿងអលង្ការជាប់ត្រចៀក ដែលអ្នកខ្លះនៅសល់តែមួយចំហៀងប៉ុណ្ណោះ។

«ពួកយើងចេញមកចូលរួមសមោសរពណ៌ព្រះចន្ទ ហើយក៏ត្រូវគេចាប់មកទីនេះមែនអត់?»

Rose ងាកមកសម្លឹងនាយពេលឮសំណួរនេះ ធ្វើឲ្យនិស្សិតរាងកាយទាបតូចដឹងខ្លួនមកវិញថាខ្លួនកំពុងនិយាយពាក្យនេះនៅនឹងមុខម្ចាស់កម្មវិធីសមោសរផ្ទាល់។

តែ Rose មើលទៅមិនបានប្រកាន់ខឹងដូចអ្វីដែលនាយឈុនរាជមានខ្លួនឡើយ។ នាងគិតដល់រឿងសំខាន់ជាងនេះហើយនិយាយតប៖

«យើងគ្មានពេលដេញដោលនៅនេះទេ! យើងរកកន្លែងមានសេវា! តោះជួយរកគ្នា! ខ្ញុំត្រូវការទាក់ទងស្នងការ Roy ភ្លាម!»

មេពិធីការដ៏ស៊ីវិល័យរូបនេះបំបែរជំហានទៅរកទិសឧត្តរ។

វិធីសាស្ត្រប្រើត្រីវិស័យដោយកំណត់ទីតាំងតាមលំអានដានផ្កាយនាទិសខាងជើង ឈុនរាជក៏ធ្លាប់រៀនដែរ តែមិនស្មាននារីនេះហាក់ជំនាញពេកដល់ថ្នាក់មេនិស្សិតទាបកន្ទើត្រូវតាមមើលនាងមិនឲ្យឃ្លាតភ្នែក។

ចរិតលក្ខណៈមនុស្សស្រីដែលធំធាត់ឡើងនៅលោកខាងលិចដូចនាង ពិតជាពិបាករកណាស់ក្នុងប្រទេសយើង។ នាងសមតែជាប៉ូលិសស្រី។ គេគិតតែម្នាក់ឯង។

«ពិលហ្នឹងធ្វើត្រីវិស័យបានទៀត?»

នារីម្នាក់សួរមកជាភាសាអង់គ្លេស តែឈុនរាជចំណាំសំឡេងនាងបាន។ ម្ចាស់សំឡេងនេះហើយដែលបានស្រែកហៅនាយល្វើយៗឲ្យសសៀរឡើងមកតាមជណ្ដើរ ទាំងភ្នែកមើលអ្វីមិនឃើញសូម្បីមួយសរសៃ។

នាងជាកូនស្រីនាយកធនាគារ ពិន មឿង ដែលកំពុងដាក់លុយ៥០០លានរៀលជាថ្នូរនឹងការនាំកូនស្រីបានត្រឡប់មកផ្ទះវិញ។

ក្នុងក្រសែភ្នែកសិស្សច្បងកាងសាលា គេយល់ថានារីអភិជនទាំង៥មានដំណើរស្វាហាប់ហើយរហ័សឆ្លៀវឆ្លាតសឹងថាលើសពីសភាពរបស់នាងផានួនិងសិស្សប្អូនអមរាជាផង។ ពួកគេមានប្រវត្តិចេញទៅរៀននៅបរទេសយូរៗ ហើយប្រើភាសាបានយ៉ាងល្អ ថែមទាំងដឹងការណ៍រហ័សមិនទម្រន់មិនញាប់ញ័រសោះ។

សំឡេង Rose ពន្យល់ខ្សឹបៗ៖

«នៅពេលយប់ គេត្រូវចេះសម្គាល់ទិសតាមអឡ្សគោលខាងជើង មិនមែនត្រីវិស័យទេ! របស់នេះអាចប្រើខល អាចមើលម៉ោងទៀត! វាជាទូរសព្ទ ជាពិលក៏ជានាឡិកា ហើយម៉ោងនាឡិកាឌីជីថលនេះអាចជួយយើងរកទិសបានដូចគ្នា បើយើងចេះមើលវា! ពេលមេឃងងឹតខ្លាំង ការមើលផ្កាយឆ្ពោះទៅទិសខាងជើងជាវិធីល្អជាងគេ!»

«មេឃងងឹតណាស់ផ្កាយតែមួយគ្រាប់ក៏គ្មានដែរ!»

ឈុនរាជលូកមាត់ ធ្វើឲ្យគ្រប់គ្នាដែលកំពុងសម្លឹងមេឃងាកមកគេហើយខ្លះងក់ក្បាលខ្លះបញ្ចេញកាយវិការយល់ស្រប។ ប៉ុន្តែ Rose បដិសេធ៖

«ផ្កាយខាងជើងដែលពួកយើងត្រូវរកសម្រាប់ចំណាំទិស គឺវាមានជានិច្ចមិនដែលលេចទេ ប៉ុន្តែទាល់តែពិនិត្យណាស់ទើបឃើញ! យើងត្រូវការកំណត់ចុងផ្កាយនៅ Polaris តាមរយៈការស្រមៃគុណ៥ដងនៃបន្ទាត់អឌ្ឍគោលខាងជើង វិធីនេះមនុស្សបុរាណ ឬក៏ក្រុមអ្នកនិយមដើរព្រៃបច្ចុប្បន្ននេះ នៅប្រទេសអឺរ៉ុបគេតែងតែចេះប្រើស្ទាត់ហើយមិនងាយភ្លាត់ទេ។!»

ចុះយើងទៅទិសខាងជើងធ្វើអ្វីទៅ?» ពិនណាសួរបន្ថែម។

សំណួរនាងត្រូវពេលវេលាណាស់នឹងចម្ងល់អ្នកគ្រប់គ្នា ដែលកំពុងតែចំហមាត់ស្តាប់ដែរ។

Rose ដកភ្នែកចេញពីផ្ទៃមេឃ ព្រោះនាងចាំបាច់ត្រូវតែឆ្លើយសំណួរពួកគេទោះថាចិត្តមិនចង់ហើយនាងគ្មានពេលក៏ដោយ៖

«យើងមិនត្រូវទៅណាទាំងអស់ រហូតដល់យើងត្រូវដឹងច្បាស់សិនថា យើងកំពុងនៅកន្លែងណា?»

ក្មេងស្រីជំទង់កូនអភិជនម្នាក់ជ្រែកចេញមកបញ្ចេញយោបល់មិនយល់ស្រប៖

«បង Rose! ទីនេះស្រុកខ្មែរ អត់មានអីពិបាកទេបង យើងរកមើលភូមិអ្នកស្រុក ហើយសួរផ្លូវគេវិញល្អជាង!»

ឈុនរាជ គិតថា ខ្លួនឯងដឹងពីហេតុផលដែល Rose កំពុងបារម្ភ ក៏ដូចជាមូលហេតុដែលនាងមិនធ្វើចរិតអន្ទះសាដូចនារីអភិជនក្មេងៗផ្សេងទៀត។ ទីមួយ អាចថានាងទើបនឹងជាប់ទ្រុងរយៈពេលខ្លី និងទីពីរនាង ជាមនុស្សដែលប្រលូកសង្គមច្រើនហើយមានវ័យចាស់ចិត្តចាស់គំនិតជាង។

ដូចគេបានគិត មេពិធីការឆ្លើយតបវិញទាំងដកដង្ហើមយូរ៖

«នាំគ្នាគិតមើលឲ្យប្រយ័ត្នប្រយែងសិនបានអត់? យើងមិនដឹងកន្លែងនេះ ជាកន្លែងណាផង! ហេតុអីរនុកអត់មានចាក់សោ? ហើយហេតុអីបានជាគ្មានអ្នកយាម?»

ម្នាក់ៗនៅសម្ងំស្ងៀម ធ្វើឲ្យនាងនិយាយពន្យល់ខ្សឹបៗបន្ថែមទាំងតឹងទ្រូង៖

«យើងសុទ្ធតែចេញមកទាំងងងឹតងងុល! មិនដឹងថាពេលពួកវាចាប់យើងមកចេញឆ្ងាយពីភ្នំពេញចម្ងាយណា ហើយភូមិជុំវិញ បើសិនជាមានមែន អាចជាមនុស្សរបស់ពួកវាដែរទេ បានជាវាហ៊ានទុកយើងចោលគ្មានអ្នកមើលការពារ?»

ស្ងាត់ច្រៀប... គ្មានអ្នកណាមានពាក្យអ្វីនឹងតប ធ្វើឲ្យនាងនិយាយបន្ថែម៖

«កុំថាឡើយពេលនេះគ្មានសេវា! ទោះបីឥឡូវនេះ យើងខលចេញ ក៏មិនដឹងអាចប្រាប់គេថាយើងនៅកន្លែងណាដែរ!»

ឈុនរាជដែលសំងំស្ដាប់យូរហើយចាប់ផ្ដើមនិយាយវិញម្ដង៖

«មុននេះ មុនពេលចូលទៅ ខ្ញុំឮសូរទូរសព្ទខ្ញុំរោទ៍!»

ពួកគេនាំគ្នាចោលភ្នែកមករកប្រធាននិស្សិត។ សម្ដីគេពិតជាក្ដីសង្ឃឹមថ្មីមួយរបស់នារីអ្នកទោសទាំងប្រាំ។ ឃើញដូច្នេះឈុនរាជប្រញាប់ពោលបញ្ជាក់វិញ៖

«តែខ្ញុំរកវាមិនឃើញទេ! មុនមកដល់ទីនេះខ្ញុំក៏ត្រូវសន្លប់ដែរ! មិនដឹងវាជ្រុះនៅឯណាសោះ!»

Rose ប្រញាប់ប្រញាល់រកវិធី ហើយពោលសួរ៖

«រកនឹកម្ដងទៀត! រកនឹកសន្សឹមៗ! ខ្ញុំចង់ដឹងថា ឮសំឡេងពីទិសណា? ខាងណា? ម្ដុំណា?»

## ភាគទី២៩

## វគ្គ ផើងមរកតពណ៌

សំឡេងរោទ៍កណ្ដាលរាត្រី បានកន្ត្រាក់ដាស់ឧត្តមសេនីយ៍ឲ្យសើងមម៉ើងភ្ញាក់ពីដំណេក។ ការហត់នឿយកាយចិត្តប៉ុន្មានថ្ងៃមកនេះធ្វើឲ្យបុរសចំណាស់លង់ជ្រៅទៅក្នុងការលង់លក់មួយភាំងវែង ហើយដឹងខ្លួនមកវិញជាមួយក្ដីពិភាល់ថា ស្នូរទូរសព្ទថ្មើរណេះ ច្រើនតែនាំមកនូវដំណឹងអាក្រក់ច្រើនជាងល្អ។

«ប៉ូលិសខេត្តកំពង់ស្ពឺរាយការណ៍ថា គេរកឃើញឡានដែលឯកមានជិះហើយ! តែមនុស្សមិនដឹងនៅឯណា!»

«ស្អីគេវា?»

គាត់ភ្លាត់ទាំងសៅហ្មងហើយចិត្តមួយស្រមៃដល់ផានូ ដែលមានវ័យមិនច្រើនជាងកូនស្រីគាត់។

«ស្ថានភាពតួរថយន្តគឺមិនល្អសោះ ហើយមិនឃើញដានមនុស្ស មិនដឹងថាពួកគេទៅដល់ទីណាទាំងអស់! ខ្ញុំកំពុងចេញទៅខេត្តកំពង់ស្ពឺ»

គាត់រក្សាភាពស្ងប់ស្ងាត់ទោះបីថា វាជារឿងអាសន្ន។ ឱត សាម៉ុនមិនក្រោកពីគ្រែព្រោះគាត់កំពុងគិតទៅដល់ឱពុករបស់ឈុនរាជនិងគ្រួសារផានូ។ នៅតាមទូរសព្ទដែលផ្ទឹបជាប់នឹងត្រចៀក សំឡេងស្នងការ Roy លាន់ឮបន្តមកៈ

«តែខ្ញុំមានដំណឹងល្អមួយទៀត! ពួកយើងចាប់បានសញ្ញាទីតាំងរបស់ Rose!»

សម្ដីមួយឃ្លាថ្មីនេះ ពិតជាមានឥទ្ធិពលឲ្យលោកឱត សាម៉ុនក្រោកឡើងភ្លែត។ គាត់បើកភ្នែកទាំងគូដែលភ្លឺចិញ្ចាចត្រៀមស្ដាប់ពាក្យបន្តពីស្នងការក្មេង។

មិនយូរប៉ុន្មាន គេឃើញបុរសចំណាស់ទាញអាវពាក់ហើយរត់ចុះក្រោម។

ពេលនេះថ្ងៃរះច្បាស់ពេញមេឃហើយ មនុស្សជំនិតចិត្រាកំពុងអង្គុយមើលកុំព្យូទ័ររង់ចាំគាត់ក្នុងបន្ទប់តូចដែលទុកសម្រាប់ពិភាក្សាការងារ។

ឃើញរូបរាងគេតាមកញ្ចក់ទ្វារ គាត់កាន់តែពិបាកចិត្ត ហើយនឹកឃើញទៅដល់នាយ Hacker ។

ទម្លាប់ប៉ូលិសគឺមិនទុកមនោសញ្ចេតនា ការទន់ចិត្តមកលាយឡំនឹងការបំពេញភារកិច្ចស្រាប់ហើយ។ គាត់រុញទ្វារចូលទាំងដាក់ចិត្តថា នឹងសារភាពប្រាប់ពីដំណឹងអាក្រក់នៃការរកឃើញសាកសពឡានរបស់ឯកមាន ស្រាប់តែគេក្រោកមកភ្លឹបមុន ដូចជាមានអ្វីមួយប្រញាប់ត្រូវរាយការណ៍ណាស់អ៊ុំចឹង។

គេឱនគោរព គាត់ក៏សម្រួលដង្ហើមធ្វើជាញញឹមនិយាយស្វាគមន៍ៈ

«អរុណសួស្តី!»

ចិត្រាទំនងជាប្រញឹកពេកណាស់។ គេមិនមានពេលសម្គាល់ភាពស្មុគស្មាញក្នុងពន្លឺភ្នែកគូសន្ទនាប៉ុន្តែភាពច្រាស់ច្រាល់លើទឹកមុខនាយ ធ្វើឲ្យឧត្តមសេនីយ៍លូកដៃទៅក្រោយខ្នងហើយរុញទ្វារអឹបទៅវិញគ្រឹប។

«មានរឿងអី?»

គាត់សួរទាំងភ្នែករេទៅរកកុំព្យូទ័រលើដៃនាយ។ នាយស័ក្តិបួនបង្ហាញរូបរាងវត្ថុបុរាណដែលថតជាប់ផ្ចិតនៅលើ Screen ។

«វត្ថុនេះយកបានពីផ្ទះ Rose!»

គាត់ងក់ក្បាលផ្ងក់ៗ ហាក់ទុកពេលឲ្យនាយនិយាយបន្ថែម ព្រោះឧត្តមសេនីយ៍ព្រហ្មទណ្ឌធ្លាប់បានឃើញចម្លាក់មរកតពណ៌សនេះម្តងរួចហើយពេលដែលប៉ូលិសទៅឃើញទាន់ Lorenzo និងជំនួយការវឌ្ឍនៈរបស់គេក្នុងបរិវេណសួនមុខផ្ទះមេពិធីការ Rose ។

«យប់មិញនៅស្នងការជាមួយខាងស្រាវជ្រាវវត្ថុបុរាណ ខ្ញុំរកឃើញវត្ថុស្រូបសំឡេងមួយតូចបង្កប់ទុកនៅក្នុងចម្លាក់នោះ!»

ឧត្តមសេនីយ៍ជ្រួញចិញ្ចើម ភ្នែកគាត់បញ្ចេញនូវក្តីសង្ស័យរួមជាមួយការអត់ធ្មត់ចាំស្តាប់ឲ្យចប់ចុងចប់ដើមមិនបាន។

បុរសចំណាស់ពោលសួរកាត់៖

«មិនមែននាងដាក់ខ្លួនឯងទេ?»

ចិត្រាគ្រវីក្បាល ជាសញ្ញាយល់ស្របនឹងការវិភាគដ៏ខ្លីនេះ ហើយគេនិយាយបង្រ្គប់៖

«ព្រោះវាថតបានសំឡេងនាងនិយាយជាច្រើនដង! ជាប្រភេទម៉ាស៊ីនស្វ័យប្រវត្តិ មានសំឡេងកើតឡើងទើបវាលោត Record !»

«អ្នកណាដាក់ ហើយលោករកឃើញអីខ្លះ?»

«Rose ដូចជារាយការណ៍ទៅអ្នកណាម្នាក់! ខ្ញុំរកឃើញពាក្យនាងនិយាយសុទ្ធតែជាការសម្ងាត់សំខាន់ៗទាំងអស់ទាន!»

គាត់ងៀងមើលគេដោយតក់ក្រហល់សង្ស័យ៖

«ពិធីការនោះនិយាយស្អីខ្លះ?»

ចិត្រាបន្ថយសំឡេងឲ្យព្ទតិចជាងមុន ហើយឆ្លើយប្រាប់៖

«មានការសន្ទនាមួយចម្លែក! នាងដូចជារាយការណ៍រឿងហេតុទៅអ្នកណាម្នាក់ដែលនាងស្និទ្ធជាមួយ! និយាយតាមទូរសព្ទ ខ្ញុំអត់អាចឮសំឡេងអ្នកនោះសោះ ប៉ុន្តែគឺគេនិយាយអំពី Hacker!»

លោក ឱត សាម៉ុន ភ្លាត់មាត់ពាក់កណ្ដាលផ្លូវ៖

«ក្រែងនាងជាពិធីការកម្មវិធីសមោសរ មានប្រវត្តិជាអ្នកជំនាញ Fashion ទៅទាក់ទងអីជាមួយរឿងពួក Hacker!?»

បុរសនេះនិយាយបណ្ដើរ ចិត្តវិលខ្វាល់បកទៅនឹកឃើញឡើងដល់សម្ដីរបស់នាយមហារីន បណ្ដើរ «ក្រោយមកគេក្លាយជា Sponsor ធំរបស់សមោសរពណ៌ព្រះចន្ទ! មនុស្សគ្រប់គ្នាចូលរួមកម្មវិធីនេះសុទ្ធតែស្ញប់ស្ញែងភាពមានបានរបស់គេ ហើយចង់ជួបគេ! ក្រោយមកប៉ូលិសប្រកាសថាភ្ញៀវ៤នាក់របស់ខ្ញុំបានបាត់ខ្លួន! ខ្ញុំចាប់ផ្ដើមមិនសប្បាយចិត្ត! ខ្ញុំដឹងថាកូនចៅខ្ញុំ Rose បានជួយរៀបការណាត់ជួបពិសេសរវាងស្រីៗអស់នោះនឹងអាម្នាក់នោះ ខ្ញុំក៏ហៅនាងមកសួរហើយប្រាប់នាងថាខ្ញុំសង្ស័យវា! ក្រោយមកមិនដឹងនាងនិយាយនឹងវាបែបណា ខ្ញុំក៏មានអារម្មណ៍គ្រោះថ្នាក់កាន់តែចូលមកកៀក! ឡានខ្ញុំត្រូវគេផ្ដាច់ហ្វ្រាំង ហើយចុងក្រោយខ្ញុំសម្រេចចិត្តថាផ្អាកសមោសរនោះសិន!»

លោក ឱត សាម៉ុន ងាកសួរបន្ថែម៖

«Lorenzo? អ៊ីចឹងទេដឹង បានជាពេល Rose បាត់ខ្លួន វាព្យាយាមចូលទៅលួចយករូបចម្លាក់នោះចេញ? ដល់ប៉ូលិសទៅទាន់ក៏ចោទថាមានអ្នកផ្សេង?»

ចិត្រាគិតចុះឡើងហើយនិយាយតបដោយធ្វើការបដិសេធយឺតៗ៖

«ប៉ុន្តែតាមការគិតរបស់ខ្ញុំ គេទំនងជាមនុស្សផ្សេងដែលមានឥទ្ធិពលលើនាងជាង Lorenzo ទៀត! ខ្ញុំពិបាកពន្យល់ តែលោកអាចស្ដាប់សំឡេងនោះបានទាន!»

គាត់សម្លឹងមុខគេដោយពិចារណាអ្វីមួយយ៉ាងស៊ីជម្រៅ នាយស័ក្តិបួនក៏ឆ្លៀតនិយាយ៖

«សំឡេងរក្សាទុកនៅស្នងការ! មួយវិញទៀត....»

«និយាយទៅ!»

«ខ្ញុំស្ដាប់ហើយ យល់ថាស្រីម្នាក់នេះសមជាប៉ូលិស ឬមួយជាអ្នកស៊ើបការសមជាងតួនាទីជាពិធីការ!»

គេចង់និយាយថានាងមកនៅក្បែរមហាវីនក្នុងនាមជាជនបង្កប់?

«ចុះនាងជាជនបង្កប់ឲ្យអ្នកណាដើម្បីអ្វី?»

គាត់សួរប្រដេញ តាមល្បឿននៃចម្ងល់ដែលផុសចេញមកបន្តបន្ទាប់គ្នា។

ចំណែកនាយចិត្រាវិញឆ្លើយទៅតាមការយល់ឃើញ ដែលលេចឡើងមកក្នុងចិត្តវិញដូចគ្នា៖

«របៀបនាងរាយការណ៍ របៀបនាងវិភាគនិងនិយាយស្ដី នាងដូចជាកំពុងស៊ើបឲ្យអ្នកណាម្នាក់! នាងសមជាអ្នកស៊ើប!»

គាត់នៅស្ងៀម ព្រោះនេះជាតម្រុយដ៏សំខាន់ហើយថ្មីស្រឡាងមួយ។ Roy ទើបតែខលមកថារកនាងឃើញ នៅខាងណោះជាតិ ចិត្រារកឃើញការសន្ទនាសម្ងាត់របស់នាងដែរ។ តើត្រូវចាត់ការវិធីណាជាមួយមនុស្សស្រីលាក់ប្រវត្តិម្នាក់នោះ? នាងទាក់ទងនឹងសេណារីយោបាត់មនុស្សស្រីទាំង៥នាក់ក្នុងចំណែកណាខ្លះដែរ?

ចិត្រាឆ្លៀតពេលដែលឃើញបុរសមេកោយនៅស្ងៀម គេនិយាយបង្ហើយ៖

«ហើយ Rose ខ្លួនឯង ក៏ដូចជាមិនបានដឹងខ្លួនមុនទេថា ថូនេះមានប្រដាប់ស្រូបថតសំឡេង! នេះអាចនាំទៅដល់ការសន្និដ្ឋានបានថា អ្នកណាម្នាក់បានលួចសង្ស័យសមាសភាពនាង ហើយលួចបង្កប់របស់នេះដើម្បីតាមដាននាង ហើយក៏អ្នកនោះឯងដែលអាចជាអ្នកតាមធ្វើបាបនាង! មួយវិញទៀត អ្នកដែលកំពុងសហការជាមួយនាងដោយនាងកំពុងផ្ដល់ព័ត៌មាន

គ្រប់យ៉ាងឲ្យទៅគេនោះ ក៏ជាអ្នកអាចនឹងមានហេតុផលក្នុងការធ្វើបាបនាងបំបិទមាត់ដូចគ្នា!»

«គេជួលនាងស៊ើបអី ហើយក្នុងបំណងអី? ហេតុអីចាំបាច់បំបិទមាត់? លោកឮអ្វីខ្លះក្នុង File សំឡេងនោះ!?»

គាត់សួរសំណួរជាច្រើនដែលពិបាកនឹងមានចម្លើយ ព្រោះ ជាតិ ចិត្រាក៏កំពុងតែពិចារណាវែងឆ្ងាយដូចគ្នា។ បរិយាកាសស្ងាត់បន្តិច គាត់និយាយបន្ថែម៖

«ស្អីទៅធ្វើឲ្យលោកគិតថាមិនមែនតារាសប្បុរសម្នាក់នោះ?»

«ព្រោះពេលនិយាយគ្នា ពួកគេដូចជានិយាយពី Lorenzo!»

សភាពសាច់រឿងកាន់តែស្មុគទៀតហើយ។ គាត់នៅស្ងៀមដៀងភ្នែកចុះឡើងហើយដើរទៅក្បែរតុចាប់ផ្ដើមឆុងកាហ្វេឈ្ងុយពាសពេញបន្ទប់។

សំឡេងជាតិ ចិត្រាលាន់ឡើងពីក្រោយខ្នងគាត់៖

«គេនិយាយពី Lorenzo និយាយថាម៉េចខ្លះ?»

«មានឃ្លាមួយគេនិយាយថា សង្ស័យមានអ្នកណាម្នាក់ដែលចេះ Hack ខ្លាំង ហើយជួយវាយប្រហារនាយ Pravit ដែលមហាវីនជួលមកពីថៃ ម្នាក់នោះមិនមែនជា Hacker ដែល Lorenzo ជួលមកទេ ប៉ុន្តែគេនោះ ដូចមានចេតនាឲ្យខាង Lorenzo ឈ្នះ!»

«ដើម្បីអី?»

គាត់ស្ដាប់ហើយកាន់តែវិលវល់។

ទោះបីជាមាត់សួរអ៊ីចឹងក៏ដោយ ក៏បុរសចំណាស់នឹកឃើញភ្លាម ដល់ចំណុចសំខាន់ខ្លះមានសល់នៅឡើយក្នុងសំណុំឯកសាររវាង Lorenzo និងសេដ្ឋីក្មេងមហាវីន។ គាត់នឹកដល់គ្រាមួយដែលរបាយការណ៍លើកឡើងថា មហាវីនបានជួល Hacker ដ៏ថ្លៃម្នាក់មកពីភាគខាងត្បូងថៃ សម្រាប់ជ្រៀតចូលទិន្នន័យរបស់នាយ Lorenzo ប៉ុន្តែត្រូវខាងណោះដឹងខ្លួន ហើយវាយបកមកវិញទាន់ពេល។

តើនាង Rose ពិតជាអ្នកស៊ើបមែនទេ ដែលដឹងថាអ្នកទីបីណាម្នាក់បានជួយខាង Lorenzo ឲ្យផ្តួលHacker ថៃបានជាសម្ងាត់? ហើយគេធ្វើដូច្នេះមានបំណងអ្វីក្រៅតែពីធ្វើឲ្យ Lorenzo ខ្លួនឯងធ្លាប់លង់កាន់តែជ្រៅទៅក្នុងការមន្ទិលសង្ស័យពីរឿងវាយប្រហារមហាវីន ព្រោះគេដឹងថាខ្លួនពាក់ព័ន្ធនឹងការបាត់ខ្លួនពួកកូនស្រីអភិជន?

គាត់បែរមកវិញជាមួយកាហ្វេពីរពែង ហើយហុចមួយទៅឲ្យនាយស័ក្តិបួន។ ជាតិ ចិត្រាដៃម្ខាងទទួលភេសជ្ជៈដ៏ពេញនិយមនាពេលព្រឹកបណ្តើរ មាត់និយាយម៉ាត់ៗបណ្តើរៈ

«ខ្ញុំគិតថា អ្នកដែលនាងនិយាយជាមួយអាចថាស្នងការ Roy !»

បើកុំតែកាហ្វេក្តៅពេក ហើយគាត់កំពុងក្រេបថ្នមៗ មិនអ៊ីចឹងម្ល៉េះសមពាក្យនេះអាចបណ្តាលឲ្យឧត្តមសេនីយ៍ព្រហ្មទណ្ឌឈ្លក់បាន។

គេដាច់ចិត្តនិយាយពាក្យពិតចេញ ទោះបីថាមុននេះបាននៅរារែកទីទើរព្រោះតែយល់ថាបុរសកំពុងតែនៅចំពោះមុខនេះគឺជាអនាគតឪពុកក្មេករបស់ស្នងការម្នាក់នោះក៏ដោយ។ នេះព្រោះតែគេជឿជាក់ថាឧត្តមសេនីយ៍ ឱិត សាម៉ុនគាត់មានការបែងចែកច្បាស់រវាងរឿងផ្ទាល់ខ្លួននិងតួនាទី។

«Roy មានហេតុផលអីធ្វើអ៊ីចឹង? បានផលអីមកវិញ? គេជាស្នងការ!»

«តែនាងមិនប្រាកដថាធ្វើវាក្នុងបំណងអាក្រក់ទេទាន!»

«អាចថាគេទាក់ទងនាង ព្រោះរឿងក្តី ដែលពាក់ព័ន្ធនឹងកម្មវិធីរបស់នាង?»

«ទាល់តែសួរស្នងការRoy!»

គាត់ឮហើយក៏សម្លឹងមុខនាយជានិច្ច ធ្វើឲ្យចិត្រាចៀសពីការបញ្ជាក់សេចក្តីពិស្តារមិនបាន។ គេនិយាយមួយៗៈ

«ពួកគេមកពីប្រភពទឡ្ហុងដុងដូចគ្នា! អាចថាគេបានស្គាល់គ្នាជាមុនមកយូរហើយ! ដើម្បីបំបែករឿងក្តីមហាវីននិងសំណុំរឿងបាត់មនុស្ស ស្នងការអាចថាគេងមិនលក់បក់មិនល្ហើយ ក៏មានគម្រោងការស៊ើបផ្សេងដោយឡែករបស់គាត់ដែរ ហើយអាចថាចុងក្រោយនេះ គាត់បានទៅរក Rose ឲ្យជួយ!

សម្ដីនាងក្នុងអាត់ ដូចជានាងបានប្រាប់ថា បានទៅរកជួបនាយប្រាវីតដើម្បីឱ្យ បុរសថៃម្នាក់នោះបញ្ជាក់ឡើងវិញអំពីការចាញ់ដោយមិនអស់ចិត្តរបស់គេខ្លួនឯងលើលំហ Internet ហើយចុងក្រោយពួកគេរកឃើញមាន Hacker ទីបីដែលបានលូកដៃចូលថែម! បានដំណឹងនេះភ្លាម នាងក៏ប្រញាប់រាយការណ៍ទៅឲ្យស្នងការ Roy តាមទូរសព្ទដោយមិនដឹងទេថារូបចម្លាក់ក្នុងផ្ទះខ្លួន មានបង្កប់ប្រដាប់ស្រូប!»

គាត់ស្ដាប់ចប់ លួចគិតសារឡើងវិញពីសម្ដី Roy «តែខ្ញុំមានដំណឹងល្អមួយទៀត! ពួកយើងចាប់បានសញ្ញាទីតាំងរបស់ Rose!»។

ចិត្រាក្រេបកាហ្វេបន្តិច ហើយឆ្លៀតនិយាយរអ៊ូបន្ត៖

«ស្ដាយ មិនដឹងថាយើងអាចមានឱកាសជួបនាងសួរពីអ្នកណាម្នាក់នោះដែរអត់?»

បុរសចំណាស់គ្រហែមបន្តិច មុនពេលសារភាពប្រាប់៖

«ខ្ញុំទើបតែបានទទួលទូរសព្ទ Roy! គេថាចាប់បានសញ្ញារបស់ Rose ទីតាំងរបស់នាង! គេទំនងជាបានទាក់ទងដាក់អ្វីមួយលាក់ក្នុងខ្លួននាងមុនពេលពិធីការនោះបាត់ខ្លួន!»

ជាតិ ចិត្រា បើកភ្នែកភ្លឺថែស។ គេសប្បាយចិត្តដំបូងគឺការដែលសេចក្ដីសន្និដ្ឋានរបស់ខ្លួនស្ដីពីទំនាក់ទំនងប្រុសស្រីពីរនាក់នោះ កំពុងបង្ហាញភាគរយត្រូវច្រើន។ ទីពីរគឺសាក្សីដ៏សំខាន់កំពុងត្រូវបានត្រឡប់មកវិញ។

«ប្រសិនបើយើងរកនាងបានទាំងជីវិតនៅរស់ យើងនឹងវែកមុខអ្នកនៅពីក្រោយរឿងកក្កូរវ៉ល់អស់នេះបានស្រួលជាងមុន!»

គាត់ដាក់ពែងកាហ្វេចុះ ចាក់សោប្រមូលឯកសារនិងយកកាបូបហៅនាយឲ្យមកតាម៖

«តោះ!»

ចេញដល់ក្រៅទ្វារ គាត់ទំនងជានឹកឃើញ ទើបទប់ដំណើរហើយនិយាយប្រាប់នាយដោយមិនងាកក្រោយ៖

«ចិត្រា!»

«បាទ!»

គាត់ដកដង្ហើមធំមុនដាច់ចិត្តនិយាយ៖

«ប៉ូលិសខេត្តកំពង់ស្ពឺទើបនឹងរាយការណ៍រកឃើញឡានដែលឯកមានដឹកផានូទៅ! ស្ថានភាពដូចជាអាក្រក់ច្រើនជាងល្អ! មកដល់ពេលនេះ គេគ្មានតម្រុយរឿងមនុស្សទាំងអស់ដែលទៅជាមួយឯកមាននៅឡើយទេ! តែម្នាក់ក៏អត់ដែរ!»

គាត់ខំនិយាយឲ្យចប់ ព្រោះត្រូវតែនិយាយ ទោះដឹងថាអ្នកកំពុងស្តាប់គ្មានពាក្យអ្វីនឹងហាតបតមកបានក៏ដោយ។

បុរសចំណាស់បែរមករកនាយ ឃើញចិត្រាឈ្ងោកមុខធ្មឹង ដៃឱបកុំព្យូទ័រផង គាត់ក៏យកដៃទះស្មាប៉ូលិសស័ក្តិបួននេះផាច់ៗតាមទម្លាប់។

ដកដង្ហើមធំម្តងទៀត ទើបគាត់និយាយ៖

«លោកអាចស្នើសុំ Hacker ម្នាក់បាន ក្នុងករណីត្រូវការចាំបាច់និងបន្ទាន់! ប្រាប់ខ្ញុំមក!»

**វគ្គ ផ្ទះអនាគត**

នៅចម្ងាយប្រមាណជា៣គីឡូពីទីតាំងដើម ពួកគេទាំងប្រាំនាក់ដើរតាមការរុករកផ្លូវតាមទិសអឌ្ឍគោលជើងរបស់ Rose។

មេឃជិតភ្លឺ ហើយវាជាពេលវេលាដ៏ស្ងប់ស្ងាត់ ហត់នឿយនិងរួបរួមដែលមិនធ្លាប់គិតថាអាចកើតមានឡើងរវាងឈុនរាជ ក៏ដូចជា Rose និងពួកកូនស្រីអភិជនមានកប់ពពកទាំងបួននាក់នេះឡើយ ប្រសិនបើពុំមានរឿងចាប់ពង្រត់ដ៏ចម្លែកមួយនេះ។

«ខ្ទះត្នោត ក្លិនស្ករ!»

សំឡេងពិនណានិយាយឡើងដោយអំណរ។ បន្ទុះធាងត្នោតចាស់ៗនិងអុសស្ងួតផ្សេងៗទៀតពិតជាលាន់ឮប្រេះប្រោះមកក្បែរត្រចៀកនាយឈុនរាជពិតមែន។

ទោះបីយ៉ាងណា Rose ចាប់ផ្តើមខ្សឹបឃាត់៖

«យើងត្រូវប្រយ័ត្នសិន!»

សម្លឹងមើលតាម ដៃរបស់ពិនណាដែលចង្អុលទៅ គ្រប់គ្នាមើលឃើញខ្ទមតូចមួយពីចម្ងាយ បន្ទាប់មកភ្នក់ភ្លើងរោលរាលតម្កល់ពីក្រោមខ្ទះធំមួយ ក៏ជះចេញមកនូវក្លិនស្គរផ្អែមឈ្ងុយហើរមកបង្អួតតាមកម្លាំងខ្យល់។

ក្មេងស្រីម្នាក់ក្នុងចំណោមអ្នកទោសដែលមានសក់ខ្លីហើយមានផ្ទៃមុខសែនស្អាតប្រផូរ ព្រោះចាំងនឹងកាំរស្មីព្រះអាទិត្យព្រាលៗ ពេលនេះនាងសើចទាំងអំណរឡើងជាមួយវាចាខ្សឹបៗ៖

«បង Rose ផែកទៀតទៅ មានមនុស្សនៅប្រាកដជាមានសេវា!»

Rose បដិសេធ៖

«មិនប្រាកដទេ!»

នាងមានកាតព្វកិច្ចក្នុងការរក្សាសុវត្ថិភាពពួកគេ និងដឹកនាំក្រុម។ នេះជាអ្វីដែលនាងកំពុងព្យាយាមបង្ហាញដោយមិនដឹងខ្លួន ភ្លេចគិតថាឈុនរាជកំពុងតែអាក់អន់ស្រពន់ចិត្ត ព្រោះតាមធម្មតាគេនេះចូលចិត្តនាំមុខគេឯង ជាពិសេសក្នុងចំណោមនារីៗបែបនេះទៀត។

Rose បានចំណាយពេលប្រហែលជាកន្លះនាទី ក្នុងការរាវរកសេវាទូរសព្ទ ហើយទីបំផុតនាងគ្រវីក្បាលនិយាយ៖

«ចាំនៅហ្នឹងទាំងអស់គ្នា! បងចូលទៅម្នាក់ឯងសួរម្ចាស់ខ្ទមនេះរកផ្លូវទៅផ្ទះ រកកន្លែងមានសេវាទូរសព្ទ!»

ពួកគេស្ងាត់ នាងក៏និយាយប្រាប់បន្ថែម៖

«បើមានរឿងអីមិនល្អ កុំនាំគ្នាចូលមកឲ្យសោះ! ខ្លាចថា អ្នកខ្ទមនេះមានពាក់ព័ន្ធនឹងពួកអ្នកដែលចាប់យើងមកឃុំ!»

ពួកគេងក់ក្បាល អត់តែឈុនរាជ។

នៅមហាវិទ្យាល័យ គេជានិស្សិតដែលមានអំណាចនិងការគោរពជាទូទៅ។ ពេលនេះទទួលស្គាល់ថាខ្លួនឯងមានវ័យក្មេងជាង Rose តែក៏មិនព្រមធ្វើចរិតកំសាកញីដែរ។

«ខ្ញុំជាមនុស្សប្រុស! ខ្ញុំទៅល្អជាង!»

ថាចប់ប្រធាននិស្សិតចេញវឹង ទុកឲ្យ Rose ទាញអ្នកឯទៀតឲ្យថយមកពួនលាក់កាយក្បែរម្លប់ឈើតូចៗប្របផ្លូវកង់រទេះ។

វាជាព្រឹកព្រលឹមមួយពេញប្រៀបទៅដោយទឹកសន្សើម ហើយព្រះអាទិត្យហាក់កំពុងខ្ជិលជាខ្លាំងក្នុងការយាងមកបំភ្លឺលោក។ មេឃនៅតែងងឹតព្រិល ឃ្លាតគ្នា១០ម៉ែត្រមើលលែងចង់ច្បាស់។

«មានអ្នកណានៅអត់? »

គ្មានចម្លើយ... ប្រហែលអ្នកណាម្នាក់កំពុងសង្ស័យពីការបង្ហាញខ្លួនរបស់នាយ ហើយភ័យខ្លាចចំពោះវត្តមាននាយឃុនរាជវិញដូចគ្នាទេដឹង?

គេសួរខ្លួនឯងដូច្នេះ ហើយអារម្មណ៍នៅតែផ្តោតលើក្លិនស្ករ។

ខ្ទះនេះមិនអាចកូរស្ករបានដោយខ្លួនវាទេ ប្រាកដជាមានមនុស្សធ្វើ គ្រាន់តែគេនោះមិនទាន់ព្រមបង្ហាញខ្លួន។ គិតហើយគេហៅទៀត៖

«ម្ចាស់ផ្ទះ?»

«បងឯងណាគេ?»

គួរឱ្យភ្ញាក់ផ្អើលចំពោះសំឡេងមនុស្សស្រីដ៏ស្រទន់ពីរោះម្នាក់នេះ។

នាងមានវ័យ១៨ឆ្នាំយ៉ាងច្រើន បើតាមស្មាន។

ឃុនរាជបែរទៅឃ្វាំង...

**ភាគទី៣០**

នារីក្រមុំក្មេងល្អក់ម្នាក់បង្ហាញខ្លួនជាមួយនឹងសំលៀកបំពាក់ពណ៌ស្រអាប់ លើដៃនាងមានកាន់កណ្តៀវមួយផង។

របស់នោះមុតណាស់ សម្រាប់ការគិតរបស់ឃុនរាជ តែគេឃើញទឹកមុខនាងគឺស្រទន់ហួសនិយាយ។

មិននឹកស្មានថានាងមានមុខស្លូតបូតតែសម្តីចប្រាច់៖

«ខ្ញុំសួរថាបងឯងពីណាគេ?»

ផ្ទៃមុខរបស់ស្ត្រីវ័យក្មេងរូបនេះ គ្មានការព្រមានណាមួយដល់អារម្មណ៍ឈុនរាជដូចកាលចូលមកកាន់បរិវេណនេះពីដំបូងឡើយ។ គេចាប់ផ្ដើមបញ្ចេញសំឡេងសុភាពរាបសារះ

«បងវង្វេង! បងចង់ប្រើទូរសព្ទ! បងសុំខ្ចីទូរសព្ទខលបន្តិចបានទេ?»

នារីនោះសម្លឹងគេពីលើដល់ក្រោមហើយសើចះ

«នៅនេះខលម៉េចបាន?»

សម្ដីនាងមិនមែនសមជាបុប្ផាជាយព្រៃទេ។ នាងទើបតែរើមកទីនេះច្បាស់ណាស់ ក្នុងគំនិតឈុនរាជ។

ពេលស្រីតូចបោះកណ្ដៀវចោលទៅលើដី ប្រធាននិស្សិតនិយាយស្ទាបស្ទង់សួរនាងបន្ថែមភ្លាមដែរះ

«បងចង់ចេញទៅភ្នំពេញ! ចង់បានទូរសព្ទប្រើ! ជួយបងផងបានអត់?»

នាងធ្វើភ្នែកគ្រលួងៗ សម្លឹងរូបរាងប្រធាននិស្សិតពីលើដល់ក្រោមធ្វើឲ្យនាយដកដង្ហើមធំ។

«បងឯងមានរឿងអី? ពីនេះទៅភ្នំពេញមានអីឆ្ងាយ?»

ចិត្តឈុនរាជអរភើត លំដាប់តែឮថាភ្នំពេញវិលវិញមិនឆ្ងាយ។

«ហើយមើលទៅបងឯងដូចអត់បាយ? មានរឿងអីកើតឡើងទៅ?»

គេមើលទៅនាងគ្មានឃើញចំណុចណាគួរឲ្យសង្ស័យដូចកាលដែល Rose ប្រាប់ឲ្យគ្រប់គ្នាប្រុងប្រយ័ត្នលើអ្នកភូមិក្បែរៗនេះនោះទេ។  នាងសម្លឹងមកគេដោយភ្ញាក់ៗ ផ្អើលៗទំនងមកពីរូបរាងរយីករយាកដែលរត់គេចរឿងអាក្រក់ៗមក។

«ទូរសព្ទនៅឆ្ងាយពីនេះដែរអត់?»

នាងឈប់សម្លឹងឈុនរាជ ហើយសម្លឹងទៅក្រោយខ្នងនាយបន្តធ្វើឲ្យប្រធាននិស្សិតត្រូវភ្ញាក់ក្រញាងខ្លាចក្រែងមានអ្នកផ្សេងមកដល់។

គេបែរក្រោយមួយរំពេច...

ក្មេងៗមួយក្រុមបង្ហាញខ្លួនជាជួរនៅពីក្រោយខ្នងនាយមិនតិចជាង១០នាក់ឡើយ។ ក្នុងចំណោមពួកគេមានខ្លះតូចល្អិតទំនងអាយុមួយឬពីរឆ្នាំផងក៏មាន។

«ច្រើនម៉េះអ្ហះ? ក្មេងៗអស់នេះមកពីណា?»

គេសួរហើយសន្សឹមៗសើចញញឹមទៅរកពួកគេ ព្រោះថាកុមារដែលមានសម្លៀកបំពាក់មិនរៀបរយអស់ទាំងនោះស្វាគមន៍មករកប្រធាននិស្សិតនូវកែវភ្នែកភ្ញាក់ផ្អើល និងស្នាមញញឹម។

«បបរជិតឆ្អិនហើយ! ហាត់ប្រាណហើយនៅ?»

នាងសួរទៅរកពួកគេ។

នឹកឃើញដល់បុរសនេះ នារីតូចងាកមកវិញហើយឆ្លើយ៖

«បងឯងចាំបន្តិចបានអត់? ខ្ញុំរៀបបបរឲ្យក្មេងៗអស់នេះ ខ្ញុំនឹងជូនបងឯងទៅទូរសព្ទ!»

ឈុនរាជចំហមាត់ សម្លឹងទៅពួកក្មេងៗដែលប្រញាប់គ្នាទៅរកក្រាលកន្ទេលផ្ទាល់ដីហើយខ្លះទៀតរៀបចំប្រមូលចានចេញមក។

«នេះទំនងជាមណ្ឌលក្មេងកំព្រា?»

គេគិតហើយ ក្រឡេកទៅឃើញស្លាកមួយដាក់ថា «ផ្ទះអនាគត» នៅពាក់កណ្ដាលគល់ឈើធំ។

ពេលដែលយកចិត្តទុកដាក់ពិនិត្យទើបគេដឹងថា នេះមិនមែនជាខ្ទមធម្មតាប៉ុន្តែជាថ្នាក់រៀនមួយទៅវិញ។ នេះបើមើលតាមចំនួនតុវែងៗចាស់នៅខាងក្នុង។

ថ្នាក់រៀនមានកូរស្តុរ?

គេគិតទាំងអស់សំណើចម្នាក់ឯង ស្រាប់តែអ្នកណាម្នាក់កេះខ្នងដៃគេ។ គេងាកមកខ្ទាច់ឃើញក្មេងតូចប្រហែល៥ឬ៦ឆ្នាំញញឹមពព្រាយ ហើយហុចទូរសព្ទចាស់មួយមកឲ្យ។

ទូរសព្ទនេះនៅសល់តែខ្នងខាងលើ ចំណែកខាងក្រោមវាជ្រុះរោយសឹករិចរិលអស់ទៅហើយ។

កុមារាញញឹមពព្រាយ ធ្វើឲ្យចិត្តអ្នកកាងសាលាទន់ជ្រាយ ហើយញញឹមតបភ្លេចអស់ទុកកង្វល់។ គេមិនទាន់បាននិយាយអ្វីនៅឡើយ តែគេដឹងថាកុមារចិត្តបរិសុទ្ធអស់ទាំងនេះប្រាកដជាកូនអ្នកភូមិក្បែរៗដែលនាំគ្នាមករៀនអក្សរក្បែរព្រៃជាមួយនារីម្ចាស់ស្គរឆ្មោតមិនខាន។

«ទូរសព្ទហ្នឹង ខលទៅណាកើតអ្ហះអាតឿ!»

គួរអស់សំណើចឬអ្វីដែលខ្លួនមានរូបរាងបែបនេះហើយ មកឈរសន្ទនាប៉ះក្មេងមានឈ្មោះអាតឿទៀត?

ឈុនរាជញញឹមហើយសួរៈ

«អាអូនឯងមានតឿហ្នា? ម៉េចម៉ែដាក់ឈ្មោះអ៊ីចឹងឲ្យ?»

«វាអត់មានម៉ែទេ! ឈ្មោះហ្នឹងក្មេងៗដាក់ឲ្យ ហើយជាប់រហូតមកហ្នឹង!»

នាងនិយាយហើយកាន់ចានបបរមួយមកឲ្យក្មេងៗនោះផង។ ក្រឡេកឃើញឆៃប៉ូវតិចតួចនៅលាយលើចានបបរ។

«បងឯងហូបដែរអត់?»

នាងតូចនោះសួរដោយបើកភ្នែកមូលក្រឡង់សម្លឹងនាយ។

ទោះបីជាមិនដឹងថាខ្លួនឯងឆ្លងកាត់អ្វីខ្លះ និងរយៈពេលប៉ុន្មានមុនមកដល់ទីនេះ ហើយគេដឹកមកតាំងពីកន្លែងណា មកដល់ទីនេះតាមរបៀបណា នាយឈុនរាជក៏មិនមានទទួលអារម្មណ៍ថាស្រេកឃ្លានអ្វីទាំងអស់។ ទាំងនេះព្រោះតែវិបត្តិដែលបានឆ្លងកាត់ និងរឿងគួរឲ្យអាណិតនៅចំពោះមុខនេះ។

«ទុកឲ្យពួកគេទៅ!»

គេនិយាយតិចៗ តបនឹងស្រីស្អាតដ៏សប្បុរស តែភ្នែកដៀងទៅសម្លឹងក្មេងៗទាំងនេះដោយក្ដីអាសូរ។

«ប្រសិនបើទីនេះ ពិតជាទីមនុស្សធម៌សម្រាប់ក្មេងក្រីក្រអស់ទាំងនេះមកពឹងពាក់មែន ពួកគេក៏គួរតែទទួលបានជំនួយឧបត្ថម្ភ ឬសេវាកម្មអ្វីឲ្យល្អជាងនេះបន្តិចដែរ!»

នារីយកចានបបរបន្តបន្ទាប់ទៅប្រគល់ឲ្យក្មេងៗដែលរង់ចាំត្រៀបត្រា។

នៅខាងឆ្វេងខ្ទម មានគ្រែឫស្សីធំមួយហើយមានក្អមមួយចំនួន។ គេអាចទាយបានថាជារបស់របរម្ចាស់សាលានេះគឺការកូរស្ករលក់ ដូច្នេះពួកគេអាចមានលទ្ធភាពឯណាទិញត្រីសាច់មកជាអាហារពេលព្រឹក។

ព្រះអាទិត្យ ទើបនឹងរះ មានតែអ្នកជនបទចុងកាត់មាត់ញកប៉ុណ្ណោះដែលទទួលទានអាហារពេលព្រឹករហ័សយ៉ាងនេះ។

ទោះបីនាយឈុនរាជគិតដូច្នេះស្ងាត់ៗក្នុងចិត្តក៏ពិតមែន ប៉ុន្តែចិត្តគេក៏មានដំណាលគ្នានូវគម្រោងការជាច្រើនប៉ងថាជួយដល់ក្មេងៗទាំងនេះ ប៉ុន្តែគេមិនដឹងទេថានឹងចាប់ផ្តើមពីណាទៅ ព្រោះខ្លួនក៏ស្ថិតក្នុងសភាពមិនទាន់ដឹងផុតគ្រោះហើយឬនៅផង។

«ម៉ោះ! ខ្ញុំជូនបងឯងទៅផ្សារ និយាយទូរសព្ទ!»

ឥឡូវនេះ ស្រីតូចមកវិញជាមួយម៉ូតូសង់កូរ៉េកញ្ចាស់មួយ។

លក្ខណៈរបស់នាងគឺជូនគេចេញទៅចោលក្រុមក្មេងៗអស់ទាំងនេះ។ វាអាចបង្ហាញបានថាទីនេះមានសុវត្ថិភាព។

គេបង្វិលក្បាលងាកមួយឆ្វាចរកមើលគ្នាខ្លួនដែលកំពុងពួន ហើយមើលគ្រប់ទិសទីក្រែងឃើញជនចម្លែកណា។

ក្រៅពីក្រុមកុមារស្លូតត្រង់ដែលកំពុងសប្បាយនឹងវេលាអាហារដំបូងប្រចាំថ្ងៃរបស់ពួកគេ គ្មានឃើញអ្នកណាទៀតគួរឲ្យសង្ស័យឡើយ។

គេញញឹមទៅកាន់ទីនោះសាជាថ្មី ទីដែលពួកនារីអ្នកមានកំពុងស្ថិតនៅជាសញ្ញាសម្ងាត់ឲ្យពួកនាងរង់ចាំគេចេញទៅរកសេវាទូរសព្ទហើយនិងត្រឡប់មកវិញ។

បន្ទាប់មក គេឈានយឹតៗឡើងម៉ូតូដែលនារីកូរស្ករកំពុងបញ្ឆិះរង់ចាំ។

ម៉ូតូចេញឆ្ពោះទៅរកផ្លូវដីក្រហម សូរសៃងស្រទោរស្រទន់នៃទិនករដែលនៅតតាំងជាមួយសន្សើមពេលព្រឹកត្រជាក់ស្រស់ស្រាយ។

«នេះខេត្តអីស្រុកអី?»

«ដែនសីមាកំពង់ស្ពឺនិងកោះកុង!»

ឈុនរាជហួសចិត្តគេនិយាយរអ៊ូ៖

«គិតអីចេះខុស! នៅជិតបង្កើយ!»

ស្រាប់តែនាងតបវិញផ្ទុង៖

«បងឯងស្មានថាជិតហ្អី? ពីនេះទៅផ្សារ៩គីឡូ!»

«អ្ហះ?»

គេនិយាយផ្ទាន់បានតែមួយម៉ាត់នេះគត់ ព្រោះហួសចិត្តពេក។ នារីនេះឮហើយក៏ញញឹម។ ទោះបីជាគេបានត្រឹមឃើញតែថ្ពាល់នាងពីក្រោយក្ដី បុប្ផាជនបទពិតជាមានសោភ័ណ។ ស្បែកនាងពណ៌ទឹកឃ្មុំ លឿងថ្លា រលោងហើយស្រឡូន។ ដៃនាងមិនសមជាអ្នកដែលធ្វើការធ្ងន់ ឬកូរស្ករត្នោតនោះឡើយ។

អ្នកណាកំពុងលេងអីបន្លំយើង? យើងនេះងាយម្លេះឡើងជិះម៉ូតូហើយទៅណាជាមួយនាង? តើគេនាំយើងទៅណាទៀតហើយ?

«ចង់និយាយថាយើងត្រូវជិះ១៨គីឡូទាំងទៅទាំងមក?»

«ចាស! តែហើយចុះបងឯងមកវិញធ្វើអី? ទៅដល់ផ្សារហៅអ្នកផ្ទះមក បងឯងឡើងឡាន ឈ្នួលទៅភ្នំពេញក៏បាន!»

នាងមិនដឹងទេថាចិត្តឈុនរាជនៅនឹកគិតដល់នារី៥នាក់ ដែលជ្រកពួនក្បែរសាលាខ្ទមកម្សត់នោះនៅឡើយ។

គេគ្រហែមយកសំឡេងបន្តិច តែតាមពិតរកនឹកល្បិចមកដោះសានិងស្ទាបស្ទង់មើលកិរិយាស្រីតូចនេះផង។

«បងចង់ទៅលាក្មេងៗអស់នោះ! បងស្មានថាជិត! ហើយចុះយើងចេញមកឆ្ងាយអ៊ីចឹងបានអ្នកណាមើលពួកគេ?»

«មើល? ក្មេងៗទាំងនោះចេះណាស់ មិនចាំបាច់មានអ្នកណាមើលពួកគេទេ!»

នាងនិយាយធ្វើហីដែលស្តាប់ទៅគួរឱ្យភ្ញាក់ផ្អើល តែគេរក្សាកិរិយាធម្មតាហើយឆ្លើយតប៖

«នៅភ្នំពេញ ក្មេងៗអាយុក្រោម១២ឆ្នាំត្រូវតែមានមនុស្សចាស់នៅក្បែរ!»

ស្រីតូចសើចកក្អឹក ធ្វើឲ្យបងកាងសាលាកាន់តែភ័ន្តភាំងនឹងកិរិយារបស់នាង។

«ចុះបងឯងថាមើល ខ្ញុំអាយុប៉ុន្មាន?»

ឈុនរាជអស់ពីភ័ន្តទៅជាគ ហាមិនចេញនឹងអាកប្បកិរិយារបស់នាង។ នាយឆ្លើយដាច់ៗ ពេលឃើញនាងជិះម៉ូតូក្រវិចក្រវៀនចុះឡើងតាមចង្អូរផ្លូវដែលច្រោះដោយសារសំណល់ទឹកភ្លៀង។ នាងហាក់ស្ទាត់តែម្តង គឺស្ទាត់ស្ទើនឹងបិទភ្នែកក៏បញ្ជាម៉ូតូកាត់ផ្លូវដ៏លំបាកនេះបានដែរ។

«ម៉េចអូនឯង មិនគិតថាបងនេះជាមនុស្សមិនល្អ?»

«ចុះខ្ញុំមានអីឲ្យបងឯងយក?»

ឈុនរាជមិនឆ្លើយបែរជាសួរវិញ៖

«ចុះមកនៅអីឆ្ងាយម៉េះ? មានអ្នកនៅក្បែរៗផ្ទះអនាគតហ្នឹងអត់?»

នាងឆ្លើយតបវិញធ្វើហី៖

«ថ្ងៃអនាគតច្បាស់ជាមានហើយ!»

«អូយបងស្តាប់យើងយូរទៅវ៉ល់ទៅហើយនៀក!»

ឈុនរាជឈ្លីក្បាល។

នាងសើចក្អឹកៗ ហើយបន្ត៖

«ហ្នឹងខ្ញុំមិនទាន់ដាក់គណិតសួរបងឯងផង!»

«អ្ហះ?»

នាងបន្តសើច គេងឺងើជាមួយចរិតដ៏ចម្លែកនេះ។ តែក៏គួរឲ្យស្រលាញ់ម្យ៉ាង។

គេនិយាយបន្តពី «អ្ហះ» ដ៏កំបុតនោះ៖

«នែ៎! ហើយយើងឈ្មោះអី? ពូកែនិយាយពាក្យដាក់ Password ម៉េះ? ហើយចុះយើងបង្រៀន គណិតមែន គ្រូគណិតល្អិត?»

នាងងាកមកឆ្វេងបន្តិច បង្ហាញចិញ្ចើមងឿងឆ្ងល់ តែស្រស់ផូរផង់៖

«Password អី? បងឯងគិតថាខ្ញុំមិនស្គាល់ Facebook? ខ្ញុំមិនមែនគ្រូគណិត តែខ្ញុំសិស្សពូកែគណិតខេត្តកំពង់ស្ពឺ!»

«ម៉ាខេត្តកំពង់ស្ពឺ? ហើយស្គាល់ Facebook ទៀត ក្មេងខូច!»

គេរអ៊ូបន្ទោស ទាំងស្រលាញ់ចរិតស្រស់ស្រាយរបស់នាង។ នាងញញឹមមិននិយាយអ្វី នាយចរចាបន្ថែម៖

«បងឈ្មោះឈុនរាជ!»

«ឈ្មោះបងឯងដូចតារាចម្រៀង! ខ្ញុំឈ្មោះសន្យា ឈ្មោះក្នុងហ្វេសប៊ុក SNYA!»

«អង់គ្លេសចំណាប់យើងហ្នឹង?»

«ខ្ញុំមាន Account បីគឺ SNYA ផ្ទះអនាគត និង SNYA fake!»

«អ្ហះ?»

គេភ្លាត់មាត់ពាក្យខ្លីដដែល ហើយនឹកឃើញអស់សំណើច ដល់វេននាយខ្លួនឯងជាអ្នកសើចក្អាកក្អាយផុតអស់ទុកព្រួយកង្វល់។

«បងឯងសើចស្អី?»

ស្រីតូចនិយាយទាំងលាយសូរសំណើចជាមួយសំនៀងនាងផង។

«យើងជាអ្នកណាឲ្យច្បាស់នៀក មកនៅក្នុងព្រៃ កូរស្ករម៉ាខ្ទះធំ ហើយចិញ្ចឹមកូនមួយហ្វូង! មានFacebook ដល់ទៅ៣ មកប្រាប់គេប្រាប់ឯង! ហើយfacebook គេគ្រប់គ្នាគេខំដាក់ហ្សីនដាក់ True ដាក់ Real យើងវិញដាក់ Fake?»

«អ៊ីចឹងសើចដែរ?»

«បងសួរមែនទែន! យើងពិតជាទៅ៩គីឡូ? ហើយក្មេងៗអស់នោះថ្ងៃត្រង់បានអីហូប?»

«ហើយ៩គីឡូបងឯងជិះដល់ថ្ងៃត្រង់?»

នាងសួរតបវិញធ្វើហី។

ឈុនរាជអេះក្បាលឆ្លើយ៖

«អីចុះ... យើងទៅវិញមិន១៨គីឡូសរុបអ្ហះកំពូលគណិត? មេគណិតល្អិត? ហើយផ្លូវពិបាកយ៉ាងនេះយើងចង់ស៊ុតយកប៉ុន្មានគីឡូក្នុងមួយម៉ោង?»

«រឿងខ្ញុំទេ! សំខាន់ឲ្យតែបងឯងទៅដល់ឡានឈ្នួល បានរកផ្ទះឃើញទៅ!»

ទោះមើលទៅនាងស្លូតត្រង់កម្រិតណាក៏ដោយ រឿងអាសន្នដែលទើបនឹងកើតឡើងថ្មីៗនៅក្នុងជីវិតបានធ្វើឲ្យគេស្លុងគិតសារដើមឡើងវិញពេលឮពាក្យថា «ផ្ទះ»។

គេនឹកដល់សុវត្ថិភាព នឹងសេចក្តីមន្ទិលជាច្រើន ដែលញ៉ាំងឲ្យនារីអ្នកមានស្តុកទាំង៥មិនអាចបង្ហាញខ្លួនចេញមកបាន។

តែគេនៅតែមិនដាច់ចិត្តនិយាយរឿងនេះនឹងក្មេងឈ្មោះសន្យា អំពីការពិតដែលថាចិត្តគេពេលនេះនៅតែចង់បកក្រោយយកមិត្តប្រាំនាក់ទៀតឲ្យមកជាមួយគ្នា។

«ខ្ញុំសុំម្ចាស់ទឹកម្ចាស់ដីឱ្យគ្រប់យ៉ាងដំណើរការទៅដោយរលូនល្អ!»

គេគិតទាំងស្ងាត់ស្ងៀម ធ្វើឲ្យនាងអផ្សុកហើយសួរបកវិញ។

«បងឯងដឹងអ្ហែ? ហេតុអី ខ្ញុំដាក់វាថាផ្ទះអនាគត?»

គេដាក់អារម្មណ៍ត្រឡប់មកវិញហើយសួរបន្លប់ ព្រោះគេគ្មានចម្លើយតបនឹងសំណួរនាង៖

«អ៊ីចឹងផ្ទះហ្នឹងអូនអ្នកដាក់?»

«ព្រោះអនាគតរបស់ខ្ញុំគឺនៅទីនោះ ហើយទីនោះនឹងក្លាយជាសាលារៀនធំមួយ!»

ឈុនរាជនៅស្ងៀម។

បើកុំតែគេកំពុងនឹកគិតទៅដល់នារីទាំងប្រាំ ម្ល៉េះសមនារីតូចម្នាក់នេះ ពិតជាប្រធានបទដ៏គួរឲ្យចម្លែកនិងរំភើបមួយ។

«ទៅធ្វើសាលាអីជ្រៅម៉េះ? ដល់៩គីឡូពីផ្សារ អ្នកណាគេទៅរៀន?»

«បងឯងមិនដឹងទេថា មានភូមិអ្នកព្រៃច្រើនណាស់!»

«អ្នកព្រៃ?»

«អ្នកដែលរស់ពឹងលើព្រៃ ហើយនិងធ្វើគ្រឿងប្រពៃណីលក់! ពួកគាត់មិនចេះមករស់ក្នុងសហគមន៍ពាណិជ្ជកម្មទេ! គាត់រស់ពឹងតែលើធម្មជាតិ! អ៊ីចឹងបងឯងឃើញអត់! ពេលធម្មជាតិកាន់តែត្រូវបានបំផ្លាញឲ្យហោចៗទៅ! គាត់ត្រូវដកថយមកកាន់តែឆ្ងាយៗ ហើយកូនៗរបស់គាត់ក៏មិនបានទៅសាលារៀនជាប់លាប់ព្រោះ…..»

«អ្ហូយសម្ដីដូចមនុស្សចាស់!»

គេជជែកទាំងចិត្តនឹកឃើញភ្នកទៅដល់គុកក្រោមល្អាង។

សម្ដី «អ្នកព្រៃ» របស់នាងធ្វើឲ្យចិត្តនាយជ្រួលខ្វល់។

«អូនអ៊ំា្ហបងសួរមួយ! អូនឯងដែលឮកន្លែងម្ដុំៗហ្នឹងមានល្អាងមានអីអត់ហ្នឹង?»

នារីនេះនៅស្ងៀមផ្ងៀងក្បាលចុះឡើងទំនងជារកនឹក។

ចំណែកប្រធាននិស្សិតមិនឮចម្លើយ ចិត្តនាយរឹតតែច្រាស់ច្រាល់។

នាយងើបភ្នែកសម្លឹងបកក្រោយ ប៉ុន្តែមិនអាចរកឃើញផ្លូវត្រង់ដើម្បីមើលទៅទីតាំងផ្ទះ « អនាគត» ឃើញទេ ត្បិតភ្នំពណ៌ខៀវវែងអន្លាយ លាតសន្ធឹងវែងអន្លាយស្របតាមខ្សែបណ្ដោយជាមួយពន្លឺថ្ងៃដែលរះខ្ពស់ហើយចោលកាំរស្មីមកកាន់តែច្បាស់ទែង…។

«ហើយចុះអូនឯងដែលឃើញពួកពីភ្នំពេញមកដល់ម្ដុំៗផ្ទះអនាគតដែរអត់?»

នាងរអ៊ូវិញភ្លែតៈ

«អ្ហូយអត់ដែលសោះ! ចាំឲ្យតែឃើញនឹងអាលបានដាក់ឲ្យគេសរសេរ Proposal ឲ្យ!»

«ស្អីគេ? ចេះតាំងពី Proposal ឡើង? អ្ហើយ! ហួសចិត្ត! ហើយ Proposal ហ្នឹងចង់សុំស្អីគេអ្ហះ?»

«បងឯងមិនឃើញទេ? ក្មេងៗច្រើនណាស់ សាលាធ្លាយអស់ ខែវស្សាភ្លៀងលិច! ខ្ញុំចង់បានជំនួយ! ចង់បានអ្នកគេជួយជាដំបូល ជាអគារល្មមមួយ!»

«ហើយចុះអូនឯងមិនគិតថាបងអាចសរសេរបានទេ? ម៉េចមិនឮហៅឲ្យបងជួយសោះនៀក? គិតថាបងមិនចេះឬអាម៉េច?»

នាងសើច សម្លឹងមកនាយវិញតាមកញ្ចក់ដែលមានស្នាបែកកូតមួយវែងទទឹងកាត់។

«បងឯងទំនងដែរ តែ...»

«តែម៉េច???»

«តែបងឯងកំពុងសុំឲ្យខ្ញុំជួយតើនៀក! គឺខ្ញុំកំពុងតែជួយបងឯង! បើខ្ញុំទៅសុំបងឯងវិញមានតែខ្ញុំនេះ ជា... ជា... គេហៅអីអ៊ីចេះ? ត្រូវហើយ! គេហៅថាមនុស្សឆ្លៀតឱកាស! មនុស្សហុតទឹកសម្លឹងកាក ... មនុស្ស....»

«អូខេបានៗៗៗ! បងសុំខ្លាច!»

ឈុនរាជឃាត់នាង។

នាងនៅស្ងៀមលបមើលបងប្រធានតូចល្អិតដែលសម្លក់មកពីក្រោយខ្នង។ គេនិយាយរអ៊ូបន្ថែមៈ

«និយាយសម្ដីចាក់ទឹកមិនលិច!»

«បងឯងអ្នកសួរតើ!»

«អូខេ! បងទទួលទាំងអស់! ប៉ុន្តែចង់ដឹងថា អា Proposal ដែលយើងចង់និយាយចង់បានជំនួយហ្នឹងយើងចង់សរសេរសុំអីខ្លះ?»

«តិចតួចបំផុត!»

នាងនិយាយទាំងមុខប៉ព្រឹម។

«អូខេ! និយាយមកក្រែងបងជួយបាន!»

គេថាទាំងបិទភ្នែកសម្រាក ព្រោះហត់ត្រចៀកជាមួយក្មេងស្រីសម្តីរយលាន ស្រាប់តែនាងនិយាយមកទៀតវ៉ាវ៖

«ចង់បានអណ្តូងទឹក៧៨! »

គេបើកភ្នែកមកវិញខ្វាក ហើយស្រីតូចនិយាយបន្ថែម៖

«ផ្លូវ៩គីឡូម៉ែត្រនេះ ហើយនិងអគារបីខ្នងនៅផ្ទះអនាគត!»

ប្រធាននិស្សិតគោះស្មានាងពីក្រោយ ហើយនិយាយបន្ទោសតិចៗ៖

«អាហ្នឹងទាល់តែបងបញ្ជូនឯងឲ្យទៅរក Lorenzo ហ្មងទៅ! សុំតិចពេកអ៊ីចឹង! អស្ចារ្យណាស់ អណ្តូងជិតមួយរយ ហើយផ្លូវ៩គីឡូ! »

ពីក្នុងកញ្ចក់មើលគ្នាឃើញ នាងធ្វើមុខញញឹមប្រិមប្រិយដូចបុប្ផាត្រូវទឹកសន្សើម ដូចស្លាន់ត្រូវភ្លើងមិនចេះស្គាល់ក្តៅ។

ភាគទី៣១

នារីតូចល្អិត ចរចាបន្តជាមួយសម្តីរបស់ឈុនរាជ៖

«អ្នកណាគេLorenzo? បរទេស? បារាំង??? អត់ខ្វល់! ឱ្យតែគេប្រាកដជាព្រមជួយមែន ខ្ញុំខ្លាចអីទៅជួបគេ ស្មានថាខ្ញុំមិនចេះនិយាយ អ្នកស្ម័គ្រចិត្តសាសន៍គេអី ខ្ញុំធ្លាប់ស្គាល់ហើយទាំងអស់ ខ្ញុំបង្រៀនជនជាតិភាគតិចក្នុងព្រៃឱ្យលែង Facebookបង្កើតpage កុលសម្ព័ន្ធទៀត បងឯងជឿអត់ថ្ងៃណាមួយ ខ្ញុំរកលុយបាន ខ្ញុំនឹង Boost page ជនជាតិក្នុងព្រៃឱ្យគេស្គាល់ពេញប្រទេសម្តង!»

«អ្ហូយ boost Pageទៀតព្រះនាងប្អូន??? រយៈទ្រូងអាបងឯណោះ!»

ស្នូរឡានប៉ូលិសលាន់មកពីចម្ងាយ......គេឈប់និយាយហើយឆ្លេឆ្លាផ្ទៀងត្រចៀកស្តាប់.....។

ដំបូងឈុនរាជហាក់ចង់ភ័យ តែគេនឹកឃើញវិញមួយរំពេច៖

«រឿងអីយើងត្រូវភ័យ? បើពួកគេជាប៉ូលិសប្រាកដមែនហេតុអីយើងមិនរកគេឱ្យជួយគ្នាយើងប្រាំនាក់ទៀតដែលកំពុងរង់ចាំ?»

នាយកេះខ្នងស្រីតូចនេះហើយនិយាយភ្លាម៖

«អូនអ្នា ផ្ទះអនាគតមានផ្លូវចូលផ្សេងក្រៅពីផ្លូវដែលយើងកំពុងតែជិះនេះដែរអត់?»

នាងឆ្លើយវិញស្រួយស្រឹប៖

«ឆ្ងល់បងឯងដល់ហើយ! មកសួរអ៊ីចឹង? កន្លែងណាក៏មានផ្លូវចេញពីរបីខុស គ្នាដែរណ៎ាបង! កុំឡើយព្រៃធំយ៉ាងនេះ!»

«ជុំវិញនេះក្រៅពីល្អាងភ្នំនៅមានព្រៃទៀត?»

«អ្វួយមើលបងឯង? ស្រុកព្រៃមិនឱ្យមានព្រៃ?»

គេលេបទឹកមាត់ហើយគ្មានពេលសូម្បីតែខឹងនាង ក៏គ្មានពេលសូម្បីតែគិតផងដែរថា តើប៉ូលិសទាំងអស់នេះ អ្នកណាជាអ្នកហៅមក។

«បងសុំទោសសន្យា! បងចង់បកក្រោយ!»

«បងឯងកើតអី?»

នាងសួរតបវិញហាក់មិនយល់អ្វី។

គេប្រញាប់ឆ្លើយ៖

«បងនឹងពន្យល់យើង! ទៅផ្ទះអនាគតវិញសិនទៅបានអត់?»

ទីបំផុតស្រីតូចបន្ថយល្បឿន ហើយចុងក្រោយនាងព្រមបែរចង្កូតបកក្រោយ។

វគ្គ ទំនាក់ទំនង Rose និង Roy

ស្នូរឡានប៉ូលិសកប់បាត់ស្ងាត់ក្នុងរលកទឹកចិត្តភ័យព្រួយលាយអររបស់ប្រធាននិស្សិត។ គេត្រូវបានសន្យាជូនមកដល់ ផ្ទះអនាគតចំពេលដែលគេឃើញRoseចូលមកអង្គុយក្នុងឡានរបស់Roy ទៅហើយ។ ស្រីៗកូនអ្នកមាននៅព័ទ្ធជុំវិញលើគ្រែឫស្សីនៃផ្ទះអនាគត ម្នាក់ៗកំពុងប្រញឹកគ្នានិយាយទូរសព្ទ។

ស្រីតូចឈប់ម៉ូតូយឺតៗ ទាំងពាក់កណ្ដាលស្រលាំងកាំង។

«គេមកថតកុនអីនៅហ្នឹង?»

ឈុនរាជ ចុះផងជូតញើសផង។ គេសម្លឹងគ្រប់គ្នាហើយឃើញRoseមើលមកគេ។ គេឃើញស្នងការកំពុងឆ្ការដៃជើងជាមួយកងរាជអាវុធហត្ថខេត្ត ពីរបីរូបដែលមានឯកសណ្ឋានត្រឹមត្រូវ។ ចំណែកសូរឡានប៉ូលិសនៅតែលាន់ល្វើយមកពីឆ្ងាយបន្តឡើងវិញ។

ឈុនរាជនិយាយនិងសន្យាដែលកំពុងចំហមាត់៖

«គេមិនមែនថតកុនទេ! តិចទៀតប៉ូលិសមកជុំវិញនេះកាន់តែច្រើន ហើយពួកព័ត៌មានទូរទស្សន៍ល្បីៗក៏នឹងមក ដល់ដូចគ្នា!»

សំឡេងស្នងការRoyលាន់មកក្បែរខ្នង៖

«អ្នកនាង សូមអញ្ជើញឡើងឡាន!»

សន្យានិងឈុនរាជងាកទៅសម្លឹងពួកនារីៗអ្នកមានដែលស្នងការកំពុងដើរសំដៅមករកហើយក្រុមកងរាជអាវុធហត្ថខេត្តក៏កំពុងតែអមដំណើរ។

«សូមឡើងឡានកងរាជអាវុធហត្ថ ពួកយើងនិងជូនដំណើរអ្នកនាងទៅភ្នំពេញ!»

នារីៗបើកភ្នែកមូលក្រឡង់សម្លឹងគ្នាទៅវិញទៅមកដោយប្រយ័ត្នប្រយែង។ ពួកគេស្ថិតក្នុងស្ថានភាពដូចជាឆ្មាដែលធ្លាប់ត្រូវទឹកត្រជាក់ឥឡូវនេះសូម្បីតែប៉ះទឹកក្ដៅក៏ខ្លាច។

«ខ្ញុំចង់ចាំអ្នកផ្ទះសិន!»

ពិនណានិយាយស្ទាក់ស្ទើរតែនារីម្នាក់ផ្សេងនិយាយបដិសេធ៖

«អត់ទេ! ខ្ញុំចង់ចេញពីទីនេះ!»

ឈុនរាជងាកទៅសម្លឹងពួកគេចំពេលនារីទីបីងាកមកសុំជំនួយគំនិតពីគេ៖

«បង! បងឯងអ្នកជួយពួកខ្ញុំ បងឯងនិយាយទៅ ពួកគេនេះទុកចិត្តបានដែរអត់?!»

ដល់វេនសន្យានារីជនបទ ត្រូវបង្ហាញអាការៈង៉េមង៉ាមមិនដឹងស្ដាប់យល់អ្វីមួយឱ្យប្រាកដ។ បុរសតូចល្អិតដែលពឹងឱ្យខ្លួនជូនឧបទៅផ្សារតាមពិតបានជួយអ្វីដល់ស្រីស្អាតៗអស់ទាំងនេះ?

នាងគិតហើយងាកមកតាមដានរង់ចាំមើលប្រតិកម្មរបស់ឈុនរាជ។

នាងពិតជាឃើញបុរសទាបល្អិតមិនបដិសេធអ្វីនិងសម្ដីស្រីស្អាតនោះសោះ បានន័យថា គេពិតជាស្គាល់គ្នាពីមុនមកពិតមែនហើយក៏មិនភ្ញាក់ផ្អើលបន្តិចណាពេលឃើញមនុស្សចម្លែកអស់នេះនៅ«ផ្ទះអនាគត» របស់នាងទៀត តើមានន័យថាម៉េច?

«ម្នាក់ហ្នឹងនិយាយរកបងឯងមិនមែន?»

នាងទាញអាវនាយសួរ ធ្វើឱ្យប្រធាននិស្សិតអោនមកខ្សឹប៖

«ស្គាល់! ចាំបន្តិចចាំបងប្រាប់!»

ស្នងការRoyបែរមកសម្លឹងឈុនរាជដោយទឹកមុខស្មើ។ អ្នកកាងសាលាក៏សម្លឹងគេវិញអាការមិនញញឹនដូចគ្នា។ ឈុនរាជមិនដឹងថា តើស្នងការក្រអឺតនេះ ដឹងពីសមាសភាពខ្លួន ជាមនុស្សរបស់ឧត្តមសេនីយ៍ឱតសាម៉ុនដែរអត់ទេ ប៉ុន្តែពាក្យថា ខ្លួនជាអ្នកជួយស្រីៗទាំងនេះហាក់បាននឹងកំពុងធ្វើឱ្យស្នងការទម្លាក់ទឹកមុខ។

គេសួរមកឈុនរាជ៖

«ផានូនិងប៉ូលិសផ្សេងទៀតនៅឯណា?»

បើគេចេះកិច្ចការប៉ូលិសមែនគេមិនគួរមកសួរដូច្នេះកណ្ដាលវាលឡើយ។

ឈុនរាជគិតហើយ បង្វែរកាយវិការធ្វើជាបន្លប់ ហើយនិយាយទៅកាន់នារីដែលសួរមុននេះ៖

«គាត់ស្នងការRoy! មានគាត់គឺមានសុវត្ថិភាព១០០ភាគរយទៅតាមគាត់ទៅ!»

ស្នងការវ័យក្មេងបានពាក្យសរសើររីកមុខវិញសន្សឹមៗ។

ពួកនារីៗ ឮតែពាក្យ«ស្នងការ»រត់សំដៅមករកនាយ ដូចមនុស្សស្រេកទឹកដើរប្រទះទន្លេ។

«មកណេះ!បងមានការចង់និយាយ!»

គេទាញនាងទៅក្បែរខ្ទះស្ករ ។ គឺនារីជនបទដ៏កាលីបឈ្មោះ«សន្យា»។ នាងដើរត្រុកៗមកតាមការអូសដៃរបស់នាយដោយទឹកមុខឆ្ងល់ហើយផ្ដោតទៅលើឡានប៉ូលិសបួនប្រាំគ្រឿងមកដល់ជាបន្តបន្ទាប់ហែគ្នា។ ភាគច្រើនរថយន្តទាំងនោះប្រើស្លាកសមត្ថកិច្ចខេត្ត។

«យើងធ្វើជាបងប្អូនគ្នាបានអត់?»

សំណួរនាយធ្វើឱ្យនាងដកអារម្មណ៍មកវិញ ហើយសម្លឹងបុរសមានល្អិតភ្លឺះៗ។

«ចាំបងជួយអូនឯងរកជំនួយសង់សាលាធ្វើអណ្តូង!»

«ប្រាប់ភ្លាមមកអ៊ីចឹង! អ្នកណាទៅជាLorenzo?គេមកទីនេះជាមួយពួកប៉ូលិសអត់ ធ្វើម៉េចបានជួបគេទៅ?»

ឈុនរាជញីក្បាលខ្លួនឯង។

នារីតូចនេះរស់នៅជើងព្រៃតែសម្តីវិញចាក់ទឹកមិនលេច ខួរក្បាលចាំមហាចាំ ប្រាប់ម្តងចាំមួយជាតិ។គេសួរជ្រួញចិញ្ចើម៖

«ហេតុអីខ្វល់ម៉េះ??»

នាងចងចិញ្ចើមឆ្លើយ៖

«ក្រែងបងឯងអ្នកថា ថាគេហ្នឹង...... មានតែគេហ្នឹងដែលអាចឱ្យអំណោយអណ្តូងខ្ញុំ! បងឯងអ្នកថានោះអី?»

«រៀនធ្វើអ្វីខ្លួនឯង កុំពូកែពឹងគេ!»

ឃើញមុខនាងហាក់ខឹង គេងាកមកនិយាយបន្លប់ជារឿងផ្សេងវិញ៖

«ចុះជំនួយក្រដូចបងដូចជាត្រីងៀត អង្ករនំទឹកដោះគោ???? មានគេចង់យកអត់?»

គេនិយាយពាក្យអស់នេះព្រោះចិញ្ចឹមចិត្តចង់បញ្ចប់ការញ៉ាំបបរលាយឆៃប៉ូវរបស់ក្មេងៗ។ នាងញញឹមវិញភ្លែតឆ្លើយតបយ៉ាងរហ័ស៖

«ស្អីក៏យកតែ ព័ត៌មានរបស់Lorenzoនៅតែយកដដែល!»

ឈុនរាជញីសក់នាង៖

«បងទៅហើយ! កុំខ្វល់ច្រើនពេក ចាំបងមកលេង យកចំណីចំណុកមក!»

គេចាកចេញឃើតៗព្រោះភ្នែកជាប់រវល់សម្លឹងមើលពួកក្មេងៗដែលឈររហង់ពីខាងក្នុងថ្នាក់រៀនហើយសម្លឹងមក។

«Add ខ្ញុំផង!ចាំAccountទាំងបីអត់?»

សំឡេងនាងលាន់មកពីក្រោយខ្នងធ្វើឱ្យឈុនរាជអស់សំណើចគ្រវីក្បាលម្នាក់ឯង។

វគ្គ ប្រអប់តូច

ស្នូរបិទទ្វារគ្រាំ ធ្វើឱ្យRoseប្រញាប់ទម្លាក់ទូរស័ព្ទចុះហើយងាកមករកស្នងការRoy។

គេនោះញញឹមញញែមនិយាយដាក់ស្រីស្អាត៖

«ឃើញអត់? ខ្ញុំថាប្រអប់ដែលខ្ញុំឱ្យទៅទុកជាប់ខ្លួន ពិតជាប្រើការបាន!»

មេពិធីការដកដង្ហើមយូរសប្បាយចិត្តដែលម្នាក់នេះមកមិនទាន់ការសន្ទនារបស់នាង។ នាងក្រឡេកទៅក្រៅកញ្ចក់ឡានសម្លឹងពួកស្រីៗដែលកំពុងនាំគ្នាដើរចូលទៅក្នុងឡានសមត្ថកិច្ច។

«មែនហើយ!! គង់តែបានវត្ថុនេះខ្ញុំបញ្ចាំងធ្វើពិល ហើយចុងក្រោយវាថែមទាំងអាចឱ្យសញ្ញាទៅលោកទៀត?»

នាងថាផង ហុចសងទៅគេផង។

គេមិនទទួលបែរជារុញឱ្យនាងវិញហើយនិយាយបែបរម្យទម៖

«ទុកជាអនុស្សាវរីយ៍បានអត់?»

នារីសិចស៊ីងាកសម្លឹងស្នងការម្នាក់នេះ។ មុខនាយក្រហមហើយមិនហ៊ានប្រឈមមុខនឹងនាងឡើយ។

«កុំប្រាប់ថា លោកញ៉ែខ្ញុំណា៎!»

«មានឯណា!»

នាងញញឹមតិចតួចហើយហុចរបស់ទៅឱ្យទៀត។

«បើមែនល្អហើយ! »

នាងស្មានថា  វាអាចបញ្ចប់ត្រឹមដែលបុរសកំសាកនេះមិនទាំងហ៊ានសារភាព អំពីអ្វីដែលចិត្តគេកំពុងគិតនោះចេញមក ស្រាប់តែគេសួរបកមកវិញខ្លីៗ៖

«ហេតុអី?»

Roseជ្រួញចិញ្ចើមឆ្ងល់ ។ស្នងការរុញឧបករណ៍ដ៏សំខាន់នេះឱ្យនាងវិញទាំងរអ៊ូបន្ថែម៖

«មនុស្សខ្ញុំឱ្យអ្វីទៅគេហើយមិនចេះយកវិញទេ!»

Roseអស់សំណើច។ នាងដៀងភ្នែកសម្លឹងវត្ថុតិចណូឡូជីដ៏ទំនើបក្នុងដៃខ្លួនក៏អាចប៉ាន់ស្មានពីតម្លៃដ៏ខ្ពស់របស់វាស្រេចទៅហើយ។

សភាពរបស់ប៉ូលិសនេះទៀតសោតនាងអាចដឹងបានថាគេកំពុងគិតយ៉ាងណា។ ទោះនារីនេះគ្មានបេះដូងមួយចំណិតឱ្យទៅនាយស្នងការតែនាងនៅតែ និយាយខ្លីៗខឹដង៖

«យកក៏បាន!មិនដឹងថាគេឱ្យយើងសុទ្ធចិត្តឬមួយក៏ទុកតាមដានយើងទេនៀក!»

«ខ្ញុំចង់ដឹងថាអាណាម្នាក់ទៅដែលនាងនឹករាល់ថ្ងៃ!»

ស្រីស្អាតថ្លោះទឹកមុខ។

នាងស្រពោនព្រោះនឹកទៅដល់Lorenzoប្រុសស្អាតក្នុងបេះដូង។ មួយរយៈពេលដែលនាងត្រូវរស់ក្នុងភាពងងឹត គ្មានមួយដង្ហើមណាដែលនាងមិនបានស្រមៃឃើញរូបគេនោះឡើយ។ ហោចណាស់នាងប្រាថ្នាសុំជួបគេឱ្យបានម្តងទៀតមុនពេលស្លាប់។

សំឡេងស្នងការក្មេងបន្លឺមកស្រាលៗ៖

«និយាយលេងទេ ចាំបាច់ខឹង?»

នាងងាកមកវិញហើយសម្រួលទឹកមុខនិយាយ៖

«អ្នកណាខឹង?!»

ស្រីស្អាតសួរហើយដាក់វត្ថុនោះត្រឡប់ទៅក្នុងហោប៉ៅខោវិញធ្វើឱ្យបុរសនេះរីកថ្ងើមសាជាថ្មី។ ទោះបីយ៉ាងណាគេមិនស្មានដល់ឡើយថានាងស៊កសៀតមកទៀត៖

«កុំសប្បាយចិត្តអត់ប្រយោជន៍! ខ្ញុំនិងលោកគ្មានថ្ងៃមានលទ្ធផលទេRoy!»

«ហេតុអី!»

បុរសនេះសួរដេញដោលទាំងមុខប្រែមកជាក្រញូវ។

«ហេតុផលសំខាន់ពីរ!»

គេមិនចង់ឮក៏និយាយកាត់៖

«ហេតុផលខ្ញុំជួយជីវិតនាង! នាងគួរតែមើលមកខ្ញុំ ហើយមានចិត្តឱ្យខ្ញុំខ្លះ?»

«មិនមែនលោកជួយខ្ញុំទេ! គេនោះ!»

នាងចង្អុលទៅរកឈុនរាជ។ នៅក្បែរឡានកងរាជអាវុធហត្ថ ប្រធាននិស្សិតលើកដៃគោរព របៀបប៉ូលិសមកកាន់នាងជាសញ្ញាកំប្លុកកំប្លែងលាគ្នាពីចម្ងាយ។

ស្រីស្អាតញញឹមទៅរកឈុនរាជធ្វើឱ្យRoyមួម៉ៅចេញឡានរឹងរាទ៍ម៉ាស៊ីនង៉ោង។

«មិញនាងនិយាយហេតុផលពីរស្មើទៅRose!»

ស្រីស្អាតតបវិញហាក់ហួសចិត្ត៖

«លោកមិនដឹងខ្លួនបន្តិចទេ? លោកមានគូដណ្តឹង ហើយអាយុក៏ក្រោមខ្ញុំ!»

«ហេតុផលប៉ុណ្ណឹងមានអីធំដុំ!»

«អ៊ីចឹង? អត់ធំដុំទៀត?តិចទៀប៉ាក្មេកលោកមកដល់ហើយ!»

«ចាំខ្ញុំសារភាពប្រាប់គាត់សុំផ្តាច់ពាក្យអមរាដា!»

នាងសើចខឹកៗធ្វើឱ្យស្នងការឆ្ងួលចុងច្រមុះនិយាយបន្ថែម៖

«ស្មានថាខ្ញុំនិយាយលេង? ខ្ញុំហ៊ាននិយាយហ៊ានធ្វើ!»

«ហ៊ានម៉េះ?»

«សម្រាប់ស្រីដែលខ្ញុំស្រលាញ់!»

នាងលូកដៃវាយស្មាគេផ្ទូង ឱ្យស្វាងចេញពីអារម្មណ៍រវើរវាយ៖

«ហេតុផលទីបី លោកមិនមែនជាមនុស្សដែលខ្ញុំស្រលាញ់!»

«ចង់ប្រាប់ខ្ញុំថា នាងស្រលាញ់មហាវីន?»

នឹកដល់បុរសនោះនាងក៏ចាប់ផ្តើមស្ទាត់សាជាថ្មីមុនពេលដកដង្ហើមធំហើយសួរ៖

«គេនោះយ៉ាងម៉េចហើយ?»

នាងគិតពីមហាវីនបុរសកន្ទាត់មានពុតត្បុតម្នាក់នោះ ឬក៏ពីLorenzoឱ្យពិតទៅ នេះជាសំនួរក្នុង ខួរក្បាល ស្នងការRoy។ គេមិនឆ្លើយនឹងសំនួរដែលនាងនៅរង់ចាំស្តាប់បែរជាចរចារឿងដទៃ៖

«ខ្ញុំចង់ឱ្យRose សហការជាមួយប៉ូលិស បកអាក្រាតអ្នកដែលចាប់ស្រីៗលាក់ទុក!»

សន្សឹមៗRoseបិទភ្នែកវិញផ្អែកខ្នងទន់ល្មៃទៅលើបង្អែកឡាន ពាក់កណ្តាលហាក់ចង់គេចវេះពីការនិយាយជាមួយនាយ ពាក់កណ្តាលទៀតនាងហាក់បីដូចជាកំពុងព្យាយាមចងចាំឡើងវិញនូវស្ថានភាពគ្រោះថ្នាក់ទាំងឡាយដែលខ្លួនទើបនឹងបានឆ្លងកាត់។

តែអ្វីដែលរំលឹកឡើងមកវិញក្នុងអារម្មណ៍នាងនាពេលនេះ មិនមែនរឿងអស់ទាំងនេះទេគឺករណីដែលស្នងការRoyចូលមកជិតស្និទ្ធនឹងនាង។

នារីនេះនឹកឃើញឡើងវិញដល់ហេតុការណ៍ប៉ុន្មានថ្ងៃមុន....

នៅច្រករបៀងអគារប៉ូលិសស្នងការម្នាក់នេះនៅតែរត់តាមនាងត្រុកៗទោះបីជានាងបង្ហាញអាការៈទើសទ័ល។

«ជឿខ្ញុំទៅ! នាងអាចនឹងគ្រោះថ្នាក់!»

ជាមួយនឹងស្បែកជើងកែងខ្ពស់ស្រួច ខោអាវរឹបរាងស៊ីវិល័យឡូយឆាយ Rose អាចធ្វើឱ្យមនុស្សទូទាំងទីនោះងាកមកមើលនាង។

«បើខ្ញុំជឿប៉ូលិស វាសនាខ្ញុំនឹងដូចមហាវីនដែរ មិនខាន!»

ទោះបីជានាងប្រកាន់អាការៈតោះតើយកម្រិតណា ស្នងការក្មេងហាក់នៅតែគ្មានត្រង់ណាប្រកែប្រកាន់នាងតបវិញសោះ។ គេនៅតែបន្តតាមនាងរហូតដល់ឡាននាងទ្រាំមិនបានងាកមកថាឱ្យ៖

«លោកមិនទៅចាប់ចោរ ឬក៏រកឃាតករទៅ! ខ្ញុំគ្មានអ្វីត្រូវនិយាយទៀតទេRoy អ្វីដែលខ្ញុំដឹងខ្ញុំប្រាប់លោកអស់ហើយ!»

«នាងមិនទាន់និយាយទេថា នាងចេញពីផ្ទះអំសម្បូរហើយ នាងទៅណា!»

ស្រីស្អាតបើកភ្នែកធំៗងាកមកក្រោយវិញពេលឮឃ្លានេះ។

នាងសម្លឹងស្នងការនេះពីលើដល់ក្រោម មុនពេលមើលមុខគេ នឹងស្នាមញញឹមរបស់ស្នងការដែលនាងកំពុងរកនឹកថាធ្លាប់ស្គាល់គ្នាពីមុនដែរឬអត់?

គេដឹងថាបានឱកាសដល់ដៃក៏និយាយមួយៗ៖

«កាលហ្នឹង ខ្ញុំទៅឡុងដុងដំបូង! ខ្ញុំទៅលេងផ្ទះអំសម្បូរនៅ Menchester ហើយខ្ញុំឃើញនាង! នាងនៅក្មេងណាស់ នាងឱ្យផែនទីមួយមកខ្ញុំ ព្រោះខ្ញុំអត់ស្គាល់ផ្លូវទេ!»

ស្រីស្អាតបង្ហាញភាពល្ងល្ងេវក្នុងភ្នែក។

នាងមិនសមថា គេរំលឹកយ៉ាងហ្នឹងហើយនៅតែមិនចាំបានទៀតទេ។

ច្រើនឆ្នាំមកនេះនិស្សិតសុភាពខ្លាចគេម្នាក់បានប្រែប្រួលមកជាស្នងការដែលនាងមើលមិនស្គាល់តែគេនៅចំណាំនាងច្បាស់។

«ក្រោយមកខ្ញុំទៅលេងផ្ទះអំសម្បូរទៀត គាត់ថានាងចេញពីគាត់លែងនៅកន្លែងគាត់ទៀតហើយគ្មានអ្នកណាដឹងថានាងទៅណាទេ! ហេតុអីចុងក្រោយនាងដូរឈ្មោះមកថាRose?»

ស្រីសិចស៊ីងាកមុខចេញលុបចោលស្នាមក្រៀមស្រពោនលើថ្ពាល់ទាំងសង បន្ទាប់មកស្រវាបើកទ្វារចូលក្នុងឡានយ៉ាងរហ័សហើយជាន់ហ្គាបញ្ឆោចេញ។

សីតុណ្ហភាពនៅខែសីហាស្រោប់រាជធានីភ្នំពេញហាក់ក្តៅស្ទុះស្ទាប់មុនពេលមេឃបង្អុរភ្លៀងនៅគ្រប់ទីកន្លែងដែលនាងងាកមើល Roseមិនអាចឃើញអ្វីក្រៅតែពីភាពព្រិលរកាំផ្សារពេញទាំងកែវភ្នែកទាំងបេះដូង។

«អតីតកាលរបស់យើង ម៉េចក៏មានមនុស្សចម្រៃម្នាក់នៅទីនេះដឹងបាន?»

ប្រៀបបី ដូចជាអ្នកដែលត្រូវបានគេហ្វឹកហាត់ឱ្យរៀនសម្លឹងមើលគ្រប់យ៉ាងពីចម្ងាយ នាងងើបមុខមកវិញពេលដឹងថាស្នងការម្នាក់នោះនៅតែមុខក្រាស់ជិះឡានដ៏ទំនើបរបស់គេតាមមកពីក្រោយនាង។

ក្នុងភាពភ្ញាក់ផ្អើល នាងរិះគិតប្រយ័ត្នប្រយែង។

ប៉ូលិសកំពុងគិតអំពីនាងក្នុងរូបភាពបែបណាគ្មានអ្នកណាដឹងទេ ប៉ុន្តែមនុស្សប្រុសម្នាក់នេះនៅសុខៗម៉េចក៏មានឫកពាប្លែកៗពេលនេះជិះឡានប្រដេញជាមួយនាងទៀត? គេកំពុងបំពេញការងារស៊ើបក្តីឬមួយគេធ្វើរឿងអ្វីឱ្យប្រាកដ?

នៅពេលដែលរថយន្តឃ្លាតចម្ងាយប្រមាណជា 20 ម៉ែត្រ ទូរសព្ទរបស់នាងស្រាប់តែលោតសារមក។

នាងមិនស្គាល់លេខដែលមានការ៉េត្រឹមត្រូវទាំងនេះទេ តែវាប្រាកដជាមនុស្សប្រុសដែលប្រដេញមកនោះហើយ ព្រោះនាងក្រឡេកឃើញពាក្យមួយឃ្លាដែលលោតមក«នាងកុំមានះជាមួយគ្រោះថ្នាក់! ស្រីៗស្អាតៗដូចនាងបាត់ខ្លួនអស់ប្អូននាក់ហើយ!»។

មេពិធីការថ្លោះទឹកមុខនាងរិះគិតចុះឡើងមុនពេលស៊ីញ៉ូអែបក្បែរបណ្ដោយច្រាំងទន្លេបួនមុខ ហើយរង់ចាំទម្រាំគេអែបមកក្បែរទើបបងស្រីស្អាតបោះសម្តីសួរ៖

«ឥឡូវនេះលោកដេញតាមចាប់ខ្ញុំទៅម្នាក់ទៀតឱ្យគ្រប់ប្រាំ?»

ពន្លឺភ្នែកRoyអណ្តែងអណ្តូងសម្លឹងមកនាងដូចជានាងស្អាតក្មេងខ្ចីគួរឱ្យចង់អោបក្រសោបការពារ ។

« ប្រសិនបើអាច អនុញ្ញាតខ្ញុំឱ្យប៉ាវកាហ្វេនាងមួយកែវទៅ! ខ្ញុំមានរឿងមួយចំនួនចង់និយាយ!»

«រឿងមហាវីន? ខ្ញុំមិនអាចជួយអីបានទេ អ្វីដែលខ្ញុំដឹងវាជាចំណែកតូចនៃការពិតប៉ុណ្ណោះ! គេនោះមានទំនាស់ជាមួយអ្នកណាធ្វើអីលើអ្នកណាខ្ញុំមិនដែលដឹង ព្រោះគេមិនដែលឱ្យខ្ញុំដឹង!

លោកចង់ដឹងរឿងច្រើនទៅសួរនាយដេវីដលេខាសំណព្វរបស់គេទៅ គេនោះហើយ ដែលដឹងគ្រប់យ៉ាងសូម្បីតែជួលHackerថៃនៅភាគខាងត្បូងមករំខានទិន្នន័យLorenzoក៏ជាគេអ្នកធ្វើ»

ទោះបីយ៉ាងណាក្រោយមកពួកគេបានព្រមព្រៀងអង្គុយញ៉ាំកាហ្វេជាមួយគ្នាក្នុងហាងទំនើបមួយ។ប្រហែលជាមកពីនាងចុះចាញ់ការប្រដេញស្និតរបស់បុរសនេះឬអាចដោយសារនាងចង់ដឹងរឿងខ្លះពីខាងប៉ូលិសដូចគ្នា?

ដៃRoseកូរកាហ្វេ យឺតៗ ហើយភ្នែកទាំងសងដ៏មានពន្លឺស្រូបទាញរបស់នាង កំពុងសម្លឹងមកនាយប៉ូលិសហាក់ចង់ឌឹដងលោកស្នងការថា តើគេនឹងនិយាយរឿងអ្វី? តើប៉ូលិសនឹងធ្វើអ្វីចំពោះនាង?

«អូខេ! ទទួលស្គាល់ថា ខ្ញុំពិតជារញ៉េរញ៉ៃបន្តិច!»

ស្នងការRoyសារភាពទាំងញញឹមស្រស់ស្រល់នឹងទឹកមុខស្មើរបស់នាង។ មេពិធីការនិយាយតបវិញវាហី៖

«លោករញ៉េរញ៉ៃខ្លាំងតែម្តង!»

កែវភ្នែកបុរសម្នាក់ ដែលគេដឹងឮ ពាសពេញទីក្រុងថា មានគូដណ្តឹងជាកូនស្រីឧត្តមសេនីយ៍ព្រហ្មទណ្ឌពេលនេះហាក់ចោលភ្នែកមើលមកនាងដូចជាមនុស្សស្រឡាញ់គ្នា?

Rose លបលួចគិតពីប្រការនេះហើយ នាងក៏ចាប់ផ្តើមកម្លាខ្លួនឯងស្ងាត់ៗក្នុងចិត្ត៖

«ល្បិចពួកប៉ូលិសអស់ហ្នឹងទេ! ស្ទីលចាស់ៗហ្នឹង! យកមនោសញ្ចេតនាមកស្ទូចយកព័ត៌មាន»

នាងលូកដៃវាសកែវកាហ្វេឱ្យកំពប់ ហើយរង់ចាំមើលការអត់ធន់របស់បុរសនេះ។

គេពិតជាក្រោកទៅរកក្រដាសមកផ្ចិតជូតបន្ទាន់។

នៅចំពោះមុខនាង Royហាក់មានកម្ពស់ស្រស់សង្ហា ខុសពីកាលដែលបាន ឃើញគេនៅឡុងដុងពីប៉ុន្មានឆ្នាំមុន។

ភាគទី៣២

«នាងស្អាតជាងពីមុនឆ្ងាយណាស់!»

គេនិយាយមករកនាងជាភាសាអង់គ្លេស ធ្វើឱ្យនាងអស់ពីតាមដានកាយវិការគេពេលនេះទៅជាភ័ន្តភាំងនឹងសម្ដីគេ។

«សូមអរគុណ! តែកុំប្រាប់ថាលោកហៅខ្ញុំញ៉ាំកាហ្វេសម្រាប់និយាយពាក្យអស់ទាំងនេះទេណា?»

Roy ដកដង្ហើមវែងៗយ៉ាងជ្រាលជ្រៅទៅក្នុងទ្រូងដូចជាខំបិទបាំងស្នាមញញឹមដែលរំភើបរាយមាយនៅចំពោះមុខនារីដ៏មានទំនុកចិត្តម្នាក់នេះ ។

«ចង់សួរអីសួរមកចុះស្នងការ!»

នាងបន្ថែម ប៉ុន្តែ Roy ឆ្លើយភ្លាម៖

«អត់ទេ! តែខ្ញុំមានព័ត៌មានសំខាន់មួយចំនួនចង់រំលឹកនាងវិធីតា!»

គេហៅឈ្មោះខ្មែររបស់នាងច្បាស់ពេក ទោះសំឡេងគេស្រាលៗក៏ល្មមឱ្យរោមភ្នែកនាងកម្រើកព្រិចចុះឡើងយ៉ាងញាប់។

«ហៅខ្ញុំRose!»

នាងខំរក្សាឥរិយាបថដើមតែRoyសម្គាល់ឃើញភាពរំជើបរំជួលក្នុងចិត្តនាងដែលបង្កប់លាក់កំបាំង។

គេញញឹមហើយលើកដៃជ្រោងសក់បង្កើនទំនុកចិត្តលើភាពស្រស់សង្ហាររបស់ខ្លួន។

«ខ្ញុំចាំនាងជាប់ក្នុងបេះដូង ឈ្មោះបីម៉ាត់នេះ!»

វាអាចជារឿងដ៏ផ្អែមល្ហែមបំផុតដែលនាងមិនធ្លាប់មានក្នុងជីវិតតែវាក៏គ្រោះថ្នាក់បំផុតដែរដែលវាចេញពីមាត់ប៉ូលិសម្នាក់។ នាងកាន់តែរំជួលចិត្ត អារម្មណ៍នាងកាន់តែបង្ខំខ្លួនឯងឱ្យមានការប្រុងប្រយ័ត្នលើសដើម។

«មិញលោកថាមានព័ត៌មានសំខាន់? អីទៅ?»

គេទាញកៅអីមកកៀកនឹងនាង ធ្វើឱ្យRose កាន់តែបង្ហាញអាការៈថានាងរងរំខាន។ ស្រីស្អាតរុញច្រានបុរសនេះ ហើយសម្លុតសួរ៖

«មានរឿងអីឆាប់និយាយមក!»

«ខ្ញុំគិតថាអ្នករងគ្រោះបន្ទាប់គឺនាង!»

Rose ក្រឡេកមើលមកRoy យ៉ាងឆាប់រហ័ស បន្ទាប់មកទាញរលាស់ចោលដៃរបស់គេដែលខំដាក់មកថ្នមៗលើប្រអប់ដៃនាង។

«កុំរលាមដាក់ខ្ញុំ កុំប៉ះដៃជើង!»

«ខ្ញុំដឹងទាំងអស់ថា ចេញពីនេះនាងនឹងទៅជួបអាម្នាក់Sponsor ធំហ្នឹង! តែអាម្នាក់ហ្នឹងហើយដែលនាងត្រូវប្រយ័ត្ន!»

«និយាយពីLoren?»

គេមិនបដិសេធហើយលើកកែវកាហ្វេក្រេបក្អឹក ហាក់ខឹងចិត្ត។ សភាពរបស់គេមើលឱ្យចំទៅដូចជាកំពុងតែមានសម្ពាធ។ គេហាក់បីដូចជាស្លន់ស្លោនឹងសុវត្ថិភាពនាង តែចិត្តមួយនាងគិតថាគេមានល្បិចកំពុងតាមដានទំនាក់ទំនងគេនាងនិងតារាសប្បុរសទៅវិញ។

ទឹកមុខស្នងការដ៏មានស្តុកនេះ គ្មានត្រង់ណាអាចឱ្យនាងទុកចិត្តបាន ទោះបីជាគេអះអាងថាធ្លាប់ស្គាល់នាងតាំងពីយូរមកហើយក៏ដោយ។

ស្រីស្អាតក្រពាត់ដៃនិយាយ៖

«Lorenzo ខ្ញុំស្គាល់គេច្បាស់ជាងស្គាល់លោក!»

សម្តីប៉ុណ្ណឹង មានឥទ្ធិពលអាចនាំឱ្យភាពអត់ធ្មត់របស់គេរុះរោយជ្រុះបាត់អស់ភ្លាម។ ស្នងការក្មេងហាក់ផ្ទុះក្តីច្រណែនប្រចណ្ឌចេញមកបានតាមពន្លឺភ្នែករបស់គេពេលឮថានារីនេះទុកចិត្តបុរសអាណិកជនខ្ពស់ជាងខ្លួន។

គេតបត៖

«គ្រប់គ្នាសុទ្ធតែទុកចិត្តវា! ខ្ញុំមិនមែនទើបនឹងឮជាលើកដំបូងទេពាក្យនេះ! ចាំសិនទៅ ចាំដល់ពេលដែលវាលៀនកន្ទុយមកអាហ្នឹងនាំគ្នាដឹងខ្លួនហើយ!»

Rose លើកកាហ្វេក្រេបទាំងភ្នែកលួចសម្គាល់មើល អាការៈឆេវឆាវនៃបុរសដែលអង្គុយពីមុខខ្លួននេះ។

«លោកស្មងការដូចជាចង់និយាយដាក់បន្ទុកថា Lorenzoជាអ្នកចាប់កូនស្រីអ្នកមានអស់ទាំងហ្នឹង?»

នាងឱនាយជាមួយនិងបបូរមាត់ដែលក្រហមដូចសេក។

«ខ្ញុំឱ្យនាងប្រយ័ត្ន!»

«រឿងផ្ទាល់ខ្លួនខ្ញុំ ដូចមិនចាំបាច់ពឹងឱ្យមានអ្នកមើលថែទេ!»

«ខ្ញុំមិនមែននិយាយក្នុងនាមប៉ូលិសទេវិធីតា!»

នាងព្យាយាមធ្វើឱ្យអាកប្បកិរិយាខ្លួនឯង មានភាពស្ងប់ស្ងាត់និងចង់ស្តាប់សមហេតុផលបន្ថែមដោយព្យាយាមស្រដី៖

«ខ្ញុំចង់ឱ្យលោកនិយាយក្នុងនាមសមត្ថកិច្ច! និយាយអ្វីមានអំណះអំណាងហើយមានហេតុផល!»

Royដកដង្ហើមធំ៖

«នាងដឹងហើយ ប៉ូលិសមិនអាចបញ្ចេញព័ត៌មានលំអិតចេញក្រៅទេ!»

ស្រីស្អាតម្នាក់នេះ ដៀងភ្នែកសម្លឹងធ្លុះចិត្តស្នងការ។ ការសម្លឹងរបស់នាងហាក់មានអត្ថន័យលើសអំពីអ្វីដែលRoyអាចកាត់ស្មាន។

គេក៏នៅស្ងាត់ស្ងៀម ឯនាងក៏នៅតែតាមដានអាការៈរបស់គេ។

ចុងក្រោយRoseដកដង្ហើមធំនិយាយ៖

«ឥឡូវនេះ ខ្ញុំគ្មានគំនិតអីទាំងអស់រហូតដល់មហាវីនដឹងខ្លួនឡើងវិញសិន!»

នាងក្រោកចេញ យឺតៗហើយបោះសម្តីចុងក្រោយស្រាលៗស្រទន់ជាងមុន៖

«អរគុណសម្រាប់កាហ្វេមួយកែវនេះ!»

នាងចាកចេញ តែមិនមែនទៅរកLorenzoដូចដែលគេគិតទេ។

ក្នុងចិត្តនាង គេកំពុងតែដើរតួនាទីជាអ្នកស៊ើបការណ៍ប្រើធម៌ត្រជាក់ ហើយគេគិតខុសហើយដោយលើកថាយកស្នេហា រឿងមនោសញ្ចេតនាមកពង្វក់នាងបាន។

ទំនាស់រវាងមហាវីននិងLorenzo កំពុងនាំវិបត្តិទៅដល់បុរសអាណិកជនដែលជាតារាសប្បុរសនោះ ព្រោះពេលនេះមហាវីននៅដេកមិនទាន់ដឹងខ្លួន ដូច្នេះគោលដៅដែលប៉ូលិសចាំបាច់ត្រូវដាក់ការសង្ស័យគឺប្រាកដជាLorenzo១០០ភាគរយ តើនឹងឱ្យនាងបកអាក្រាតពីជម្លោះពួកគេនឹងអាលប៉ូលិសមានភស្តុតាងឃាត់ខ្លួននាយឬអ្វី?

ប៉ុន្តែ ….

មិនដល់១៥ម៉ោងទៀតផងនាងបានទទួលទូរសព្ទរបស់គេ…..ចៅហ្វាយនាង សេដ្ឋីមហាវីន…..។ គឺគេខលពីមន្ទីរពេទ្យទីដែលប៉ូលិសកំពុងដាក់កម្លាំងយាមកាមការពារគេយ៉ាងម៉ត់ចត់។

«អាឡូ Rose?»

«ដឹងខ្លួនហើយ?»

Roseហាក់ភ្ញាក់ផ្អើលជាខ្លាំងដែលឮថានេះជាសំឡេងរបស់មហាវីន។ ប៉ុន្តែភាគីដែលខលមកមិនបានបណ្តោយឱ្យពេលវេលាអូសទៅយូរទេ។

«Rose ខ្ញុំទើបដឹងខ្លួនទេ អ្នកណាកោះហៅសមោសរយប់នេះ?»

មេពិធីការថ្លោះទឹកមុខ។

ការសន្ទនាបន្តទៅរហូតដល់មហាវីនដឹងថា នាងក៏មិនបាននៅពីក្រោយការកោះហៅនេះដែរ។ ពេលគេដាក់ទូរសព្ទ នាងថយមកអង្គុយលើសាឡុងហើយស្ងាត់ស្ងៀមពិចារណាម្នាក់ឯង។ ហើយចុងក្រោយ នាងលើកទូរសព្ទមកចុច…..

«ខ្ញុំមានរឿងសំខាន់ចង់ប្រាប់……»

ស្នងការRoy ឆ្លើយមកវិញទាំងត្រេកអរះ

«ខ្ញុំដូចគ្នា!»

នាងហួសចិត្ត តែសភាពការណ៍មិនអាចនៅបន្តត្រាំត្រែងបាន ទើបនាងមិនអាចបង្អង់ក្នុងការដណ្ដើមនិយាយ៖

«ខ្ញុំនិយាយមុន!»

«អូខេ! និយាយទៅ! មិនអីទេ»

នាងដកដង្ហើមធំហើយដើរទៅក្បែរបង្អួចសម្លឹងទៅខាងក្រៅសួន។

ដៃស្រីស្អាតអង្អែលលើវត្ថុបុរាណដែល មហាវីនទើបនឹងយកមកផ្ញើទុកកាលពីយប់ម្សិល។ ចិត្តនាងអណ្ដែតត្រសែតទៅដល់នាយចៅហ្វាយម្នាក់នោះ ហើយនាងក៏នឹកឃើញដល់បុរសម្នាក់ទៀតក្នុងពេលទន្ទឹមគ្នា....

«តិចទៀតខ្ញុំចេញទៅជម្រះរឿងមួយចំនួនជាមួយLorenzo!»

នាងប្រាប់Royធ្វើឱ្យសភាពរបស់ស្នងការហាក់ដូចជាកំពុងតែត្រេកអរជាខ្លាំង។ គេតបមកវិញផ្ទូង៖

«ឥឡូវនាងជឿហើយថា វានោះមិនធម្មតា!»

«អត់ទេ!!»

Rose ឆ្លើយម៉ឺងម៉ាត់មាំទាំធ្វើឱ្យ Roy ស្រងាកចិត្តនៅសំងំស្ងៀមស្ដាប់នាង។

«មហាវីនទើបនឹងខលមក គេថាមាន ការអញ្ជើញថ្មីឱ្យទៅសមោសរយប់នេះ! ខ្ញុំអត់ដឹងរឿងអីសោះមហាវីនក៏នៅក្នុងពេទ្យតើអ្នកណាធ្វើ?»

Royតបមកវិញមួយៗ៖

«ខ្ញុំនឹងទៅដល់ផ្ទះនាងឥលូវនេះ! ទុកពេលឱ្យខ្ញុំ១៥នាទី កុំភ័យRose!»

«អ្នកណាថាខ្ញុំភ័យស្នងការRoy?»

នាងនិយាយហើយងើបមុខសម្លឹងទូរទស្សន៍ដែលបន្តជាមួយកាមេរ៉ាសុវត្ថិភាពនៅជុំវិញផ្ទះ។ កាមេរ៉ា បានតាមដានរាល់សកម្មភាពនៅបរិវេណជុំវិញនេះហើយគ្រប់យ៉ាងហាក់បីដូចជា នៅធម្មតា។

នាងចាប់ផ្តើមបន្ថយសំឡេងខ្លួនឯងហើយនិយាយប្រាប់ទៅស្នងការក្មេងក្នុងអាការៈនឹងនះ

«ខ្ញុំខលនេះគ្រាន់តែចង់ប្រាប់លោករឿងសំខាន់មួយចំនួន!»

«កុំនិយាយតាមphone ខ្ញុំទៅដល់ឥឡូវហើយ!»

«ស្តាប់! ហើយបើលោករំខានពាក្យខ្ញុំទៀត ពេលខ្ញុំដាក់ចុះ លោកនឹងលែងបានឮ!»

គេនៅស្ងៀមចាញ់សម្តុតនាង។ ស្រីស្អាតចាប់ផ្តើមនិយាយមួយៗ៖

« Lorenzoមិនមែនអ្នកតាមសម្លាប់មហាវីនទេ តែសភាពទាំងអស់នេះដូចជាមានអ្នកណាម្នាក់កំពុងជះអ្វីមួយឱ្យគេប្រទ្បាក់ដូចស្វាលាបមាត់ពពែ! ខ្ញុំនឹងទៅសួរគេថាគេដឹងរឿងមានអ្នកណាម្នាក់បើកកម្មវិធីក្លែងក្លាយយប់នេះដែរអត់? »

Royនៅពិចារណាចុះឡើងមុនពេលដាក់សំណួរ៖

«នាងដូចជាប្រាកដចិត្តចំពោះម្នាក់នោះម្ល៉េះ?»

Roseបដិសេធ ៖

«ខ្ញុំជឿលើហេតុនិងផល! កាលពីអាទិត្យមុនខ្ញុំបានជួបឃុនប្រាវីតដោយចៃដន្យម្នាក់នោះហើយ ដែលLorenzoធ្លាប់ចាប់បានថាមហាវីនជួលឱ្យឆែកទិន្នន័យក្នុងបណ្តាញរបស់គេ! ម្នាក់នោះជាជើងខ្លាំង! សេវាកម្មគេថ្លៃបំផុត! ចុងក្រោយគេប្រាប់ខ្ញុំថា មានអ្នកផ្សេងជាជនទីបីបានជួយឱ្យhackerខាងLorenzoឈ្នះ! បានន័យថានៅចំកណ្តាល Lorenzoនិងមហាវីនមានអ្នកផ្សេងម្នាក់ទៀត!»

Royនៅសំងំស្ងៀមធ្វើឱ្យRose ខ្សឹបប្រាប់បុរសនេះវិញបន្ថែម៖

«លោកកំពុងស្តាប់ខ្ញុំដែរអត់?»

«ហេតុអី? វាធ្វើដើម្បីស្អី! ខ្ញុំចង់និយាយពីអាជនទីបីម្នាក់នោះ»

«ធ្វើបាបLorenzo ឬអាចថាព្រួញមួយបាញ់បានសត្វពីរធ្វើបាបទាំងមហារីន និងបំផ្លាញសមោសររបស់ពួកខ្ញុំទៀត! លោកចាប់ផ្ដើមស៊ើបពីសត្រូវរបស់ពីរនាក់គេវិញក្រែងមានផ្លូវចេញ! »

សាជាថ្មីសំឡេងស្នងការRoy ហាក់កាន់តែឆ្លេឆ្លា ៖

«ខ្ញុំមិនឱ្យនាងចេញទៅទេ! ខ្ញុំមិនទុកចិត្តពួកវាអស់ទាំងហ្នឹងសោះ Rose»

ទោះបីមាត់និយាយអ៊ីចឹងក្ដីក៏ស្នងការដឹងហើយ ថាគេមិនមានអំណាច អាចប្ដូរការតាំងចិត្តឬសកម្មភាពណាមួយរបស់នារីចិត្តដែកម្នាក់នេះឡើយ។

គេដឹងថានាងជិតបិទទូរសព្ទហើយបានជាប្រញាប់ហៅ៖

«ឈប់ៗRose! ខ្ញុំមានរបស់មួយឱ្យនាង!»

នាងហាក់ជំអក់រង់ចាំស្ដាប់ មុនពេលចុចបិទ ប៉ុន្តែសំឡេងស្នងការហាក់មានការព្រួយបារម្ភពីនាងខ្លាំងរហូតដល់ស្រីស្អាតមិនដាច់ចិត្តដាក់ចុះ តែនាងបន្ទោសគេ៖

«លោករញ៉េរញ៉ៃពេកហើយRoy»

«ប្រអប់តូចមួយ មិនដល់២ថ្នាំងម្រាម! ខ្ញុំដាក់វាស្រួបជាប់នឹងកង់ឡានក្រោយខាងស្ដាំ! នាងយកវាតាមជាប់ខ្លួន ខ្ញុំអាចដឹងទីតាំងនាងគ្រប់កន្លែង!»

Roseរភ្នែកចុះឡើងយ៉ាងរហ័សហើយបន្ទាប់មកនាងស្រាវ រែករាំងននខ្វាច់ សាជាថ្មីសម្លឹងឆ្ពោះទៅរកតួរថយន្តខ្លួនចតចោលឯក្រៅសួន។

នាងរអ៊ូទាំងសៅហ្មង៖

«ចង្រៃយក៏ អ៊ីចឹងបានលោកឯងដឹងថាពេលនេះខ្ញុំកំពុងនៅផ្ទះ!»

«កុំភ្លេចដាក់ជាប់ខ្លួន!»

នាងមិនឆ្លើយហើយបិទទូរសព្ទចោលទាំងកំហឹង។

មិនដល់១៥វិនាទីស្រួលបួលផង  នាងចុះពីផ្ទះមកដល់រថយន្ត។ ពន្លឺភ្នែកនារីនេះ ជះទៅរកកូនដុំខ្មៅមួយ ភ្ជាប់នឹងដែកកង់រថយន្តក្រោយផ្នែកខាងស្ដាំពិតប្រាកដមែន។

នាងលើកវាមកមើល.....វាមិនត្រឹមតែឆក់ជាប់ស្រួលងាយលាក់កំបាំងថែមទាំងមានប៊ូតុងចុចមួយមានប្រលោះស្រួបសំឡេងសម្រាប់ហៅលេខទូរសព្ទសម្រាប់ប្រព័ន្ធប្រតិបត្តិការស្វ័យប្រវត្តិ និងមានពិលបង្កប់។

ពេលដើរមួយៗបកចូលទៅក្នុងផ្ទះ នាងក្ដាប់របស់នេះជាប់ក្នុងដៃ តែក្រសែភ្នែកស្រីស្អាតរេរាំចុះឡើងជាច្រើនអន្លើ។

មកដល់ខាងក្នុងផ្ទះវិញ ជាមួយរយៈពេលដ៏ខ្លីបំផុតមួយ Rose អោនដាក់ភ្ជាប់វាទៅក្នុងកែងស្បែកជើងរបស់ខ្លួន។

វគ្គ ទំនាក់រវាងRose និងLorenzo

Rose ស្វាងអារម្មណ៍ចេញពីរំលឹកនឹក ដល់រឿងកន្លងផុត ។ ការគិតពីប្រវត្តិនៃវត្ថុអំណោយប្រអប់តូចខ្មៅដែលចុងក្រោយបានជួយជីវិតនាងនិងនារីកូនអ្នកមានផ្សេងទៀតពីល្អាងភ្នំគ្មានសូម្បីតែឈ្មោះ ពេលនេះអារម្មណ៍ទាំងមូលប្ដូរមកផ្ចង់លើភួយសក្បុសដែលគ្របកម្ដៅ លើរាងកាយនាង។

នាងដឹងហើយនេះគឺផ្ទះRoy។

ចេញពីព្រៃមក នាងបានមកដល់ទីនេះ ហើយប្រះដេកលែងដឹងយប់ថ្ងៃ។ សេរ៉ូមនៅព្យួរតែងរតោងក្បែរក្បាលដំណេក.....

ស្រីស្អាតងាកមកឆ្វេង សម្លឹងមើលបង្អួច នៅពីក្រោមជញ្ជាំងពណ៌ប្រាក់ តុបតែងលំអដោយអំពូលនិងផ្ទាំងសិល្បៈតូចៗ។

ពោះនាងកូររកចំណីប្រាណក៏ចង់ទៅបន្ទប់ទឹក។ មាត់បម្រុងស្រែកហៅនាយម្ចាស់បន្ទប់  ស្រាប់តែ,...

«Roseនៅឯណា?»

សំឡេងលាន់មកពីមាត់ទ្វារព្ទមិនទំនងជាជិតទេ តែមេពិធីការស្គាល់ច្បាស់ចំណាំបាន។ បេះដូងដែលទើបនឹងបានសម្រាកមួយគ្រាពេលនេះធ្វើការធ្ងន់ឡើងវិញដោយលោតរិញភឹបៗ។

«ឱត សាម៉ុន?»

នាងសួរខ្លួនឯង ដោយបើកភ្នែកគ្រលួងៗយកចិត្តទុកដាក់ស្តាប់។ ហេតុអ្វីនាងយកចិត្តទុកដាក់ចំពោះវត្ថុមានបុរសចំណាស់នេះម្ល៉េះ? នាងខ្លាចត្រូវគេដេញសួរ ពីអាថ៌កំបាំងនានារបស់តារាសប្បុរសLorenzoដែលនាងបានខំលាក់លៀមមិននិយាយជាយូរមកហើយនោះ ឬមួយក៏នាង កំពុងបារម្ភពីការដែលត្រូវបង្ខំឱ្យទៅចេញមុខធ្វើសាក្សីខាងប៉ូលិសរឿងគុកក្នុងល្អាងភ្នំ?

ទាល់តែRoseខ្លួនឯងទើបអាចឆ្លើយសំណួរនេះបាន។

«គេគេងហើយ! ពេទ្យទើបចាក់ថ្នាំឱ្យ មុននេះពីរបីម៉ោង!»

Roseដែលកំពុងផ្ទៀងស្តាប់ នាងបានឮសំឡេងស្រាលៗរបស់Royឆ្លើយតបបែបនេះ។ ចិត្តស្រីស្អាតវិលខ្វាល់ជុំវិញសំណួរមួយចំនួនថា មនុស្សប្រុសដែលពេលខ្លះមើលទៅគ្មានបានការម្នាក់នេះ ហេតុអ្វីចុងក្រោយ គេបែរជាអាចបង្ហាញសមានចិត្តមកលើខ្លួន ពិសេសថែមទាំងហ៊ានទទួលស្គាល់មុខអនាគតឪពុកក្មេក ពីរឿងដែលខ្លួននាំនាងមកស្នាក់សម្រាកមិនខ្លាចគាត់គិតផ្សេង?

ស្នូរទ្វារបិទគ្រឹប នាងកាន់តែចង់ដឹងការសន្ទនាខាងក្រៅកើនទ្វេ។

មេពិធីការច្រត់ដៃទប់ខ្លួនហើយក្រោកដើរសសៀរទៅក្បែរទ្វារបន្ទប់។

«មន្រ្តីនាយកដ្ឋានចារកិច្ច ឱ្យរបាយការណ៍មុននេះបន្តិចថា ចោរបួននាក់ដែលត្រូវយើងចាប់បានព្រោះឆ្មក់ចង់ចាប់កូនស្រីខ្ញុំនោះ គេសារភាពថាបានទទួលលុយពីដេវីដ ជំនួយការផ្ទាល់របស់មហាវីន!»

សំឡេងលោកឱត សាម៉ុននិយាយពីព្រៗកាន់តែតិចទៅៗតាមស្មានពួកគេជជែកផងបណ្តើរគ្នាចូលទៅកាន់បន្ទប់ធ្វើការរបស់Roy ផង។

«មហាវីនចាប់អមរាជាធ្វើអី?»

ក្នុងសន្ទុះរឹតតែចង់ដឹងព្រោះឮឈ្មោះបុគ្គលដេវីដមានលាយឡំក្នុងការជជែក នាងចាប់ផ្តើមសម្រេចចិត្តបង្អើបទ្វារស្តាប់។

សំឡេងRoy ឆ្លើយឡើងវិញខ្លួនឯង៖

«ខ្ញុំមិនយល់ទេ រឿងហេតុកើតឡើង ពេលមហាវីននៅដេកក្នុងពេទ្យហ្នឹង?»

ភាគទី៣៣

លោកឱត សាម៉ុនស្រដីមួយព្មមកលើ្វយតាមខ្យល់៖

«លោកប្រហែលជាកាន់តែភ្ញាក់ផ្អើលទៀតហើយRoy បើខ្ញុំប្រាប់ថាទិន្នន័យពីផ្នែកត្រួតពិនិត្យសុវត្ថិភាពបណ្ដាញinternet វិញ ក៏បានរកឃើញ បុគ្គលដេរីដនេះក៏ធ្លាប់មានទំនាក់ទំនងលួចលាក់ជាមួយម្ខាងទៀតដែរ គឺតារាសប្បុរសLorenzo»

Rose បែរខ្នងផ្អែកទ្វារ សម្រាប់ផ្ទៀងស្ដាប់ផង ភ្នែករំពៃរកមើលទូរសព្ទផង។ មានតែទូរសព្ទខ្សែ។ នាងគិតអន្ទះសាចុចឡើង ចំណែកត្រចៀកនៅតែបន្តស្ដាប់ព្ទ៖

«បើគេទាក់ទងទាំងសងខាង! មានតែគេជារនុករបស់មនុស្សទីបី?»

Royនិយាយធ្វើឱ្យឧត្ដមសេនីយ៍ប្រញាប់សួរបកវិញ៖

«មនុស្សទីបីណា?»

«Rose ធ្លាប់និយាយជាមួយខ្ញុំមុនពេលនាងបាត់ខ្លួនថា នាយប្រាវីតអ្នកHackបណ្ដាញដ៏ល្បីនៅភាគខាងត្បូងថៃត្រូវចាញ់ដៃhackerផ្សេងណាម្នាក់ដែលមានប្រភពមកពីណាមិនដឹង តែគេបានជួយឱ្យHackerខាងLorenzoឈ្នះ! ម្នាក់នោះ បើយើងគិតធម្មតាគេជួយតារាសប្បុរសឱ្យការពារខ្លួនពីមហាវីន តែបើគិតឱ្យជ្រៅគេអាចមានផែនការច្បាស់ ធ្វើឱ្យ Lorenzo ដឹងខ្លួនថា មហាវីនកំពុងតាមដាននឹងជ្រៀតចូលទិន្នន័យរបស់គេ ហើយចុងក្រោយគឺបានសម្រេចក្នុងការធ្វើឱ្យទាំងសងខាងខាំគ្នាហូរឈាម!»

ទ្រូងនាងRoseធឹតផតទៅតាមសង្វាក់ដង្ហើមនៃការជ្រួលគំនិតដែលស្ដាប់ព្ទការវិភាគអស់នេះ។

នាងខំរង់ចាំមើលប្រតិកម្មរបស់មេព្រហ្មទណ្ឌ តែមិនព្ទគាត់ថាយ៉ាងណា ព្ទតែខាងRoy និយាយមកបន្ថែម៖

«អាចថាក៏ជាមនុស្សដដែលនោះដែរ ដែលប៉ងសម្លាប់មហាវីនហើយទម្លាក់កំហុសលើតារាសប្បុរស!»

លោកឱត សាម៉ុននៅស្ងៀមទំនងជាសញ្ជឹងគិត មុនពេលនិយាយស្របតាមស្នងការ៖

«ទំនងដែរ! តាមសម្តីយប់នោះ! មហាវីននឹងអ្នកដែដល់អាចស្គាល់គ្នាពីមុនហើយគឺលេខារបស់មហាវីនផ្ទាល់ដែលជាអ្នកប្តឹងប៉ូលិស លេខាគេឈ្មោះដេវីដនោះ ពេលត្រូវ យើងសួរនៅឯស្នងការក៏ផ្តល់ចម្លើយមកដែរថា គេនៅសម្រាកក្បែរព្រលានព្រោះតែរង់ចាំទិញសំបុត្រនឹងអាលចាកចេញព្រោះហេតុផលសុវត្ថិភាព!

ចំណែកមហាវីននេះ មុនពេលធ្លាក់ខ្លួនរងគ្រោះ គេក៏ធ្លាប់ទាក់ទងជួលHacker លើផ្សាររងងឹតឱ្យតាមដានបណ្តាញរបស់តារាសប្បុរស Lorenzo ម្នាក់នោះទៀតវាស្របនឹងលោកនិយាយថារឿងពីរបីនេះដូចជាមានខ្សែសង្វាក់ទាក់ទងគ្នា ប្រសិនបើវាត្រូវបានក្រុមតែមួយបង្កើតឡើងមក! ចុះមានទាក់ទងអីនឹងកូនស្រីខ្ញុំ?ល្ងាចនោះគេចង់ចាប់នាងធ្វើអ្វី?»

Roy ឆ្លើយតបភ្លែត៖

«ហៅដេវីដនោះមកសួរ!»

«កំពុងនៅកន្លែងប៉ូលិស! គ្នាយើងកំពុងសួរចម្លើយ!»

Rose កាន់តែស្លេកមុខ។

នាងដកដង្ហើមហត់មិនដឹងថាដោយសារស្ថានភាពសុខភាពដែលទើបរួចពីទ្រុងឬមួយមកពីនាងបារម្ភដល់Lorenzoហួសហេតុ។

ស្នូរទូរសព្ទរោទ៍។ ឧត្តមសេនីយ៍ទំនងជានិយាយទូរសព្ទ តែគាត់និយាយខ្សឹបបំផុតជាហេតុធ្វើឱ្យស្រីស្អាតនៅទីនេះ ខំយ៉ាងណា ក៏ផ្ទង់ស្តាប់មិនបានមួយចម្រៀក។

ទីបំផុតសំឡេងគាត់លាន់ឮត្រឡប់មកវិញ៖

«ដេវីដសារភាពហើយ! គេថាLoren ជួលគេឱ្យសម្លាប់មហាវីន!»

Roseរំភ្ញែកគិតយ៉ាងរហ័ស ចំណែកត្រចៀកនៅផ្ទៀងស្តាប់។ សំឡេងឧត្តមសេនីយ៍នៅតែពន្យល់Roy៖

«ឥឡូវនេះ គេមានភស្តុតាងផ្ទេរលុយកាក់ពីគណនេយ្យLorenzoមកឱ្យមហាវីន! ម្នាក់នេះមានទំនាក់ទំនងជាមួយជំនួយការរបស់មហាវីនទាំងស្រីទាំងប្រុស ហើយផ្តល់ផលប្រយោជន៍

ច្រើនៗ តើគេមានបំណងអី? សូម្បីhacker ក៏ធ្លាប់ជួលវាយប្រហារគ្នាទៅវិញទៅមកទៀត លើកនេះ Lorenzoទំនងជាពិបាកលាងខ្លួនហើយ!»

នាងលែងស្តាប់។

ស្រីស្អាតរំសៀកខ្លួនមកក្បែរទូរសព្ទហើយប្រញាប់ចុច។

«លោកឆាប់លើកទូរសព្ទទៅLorenz»

ទូរសព្ទរោទ៍គ្មានអ្នកលើក......វារោទ៍ហើយរោទ៍ទៀត....ស្ទើនឹងកំសួលបេះដូងនាង។

«មានដំណឹងពីអ្នកនាងផានូទេ?»

សំឡេងឱត សាម៉ុនសួរពីចម្ងាយធ្វើឱ្យបេះដូងRose កាន់តែគាំងទ្រឹង.....ពេលនេះនាងមិនចង់ដឹងឮរឿងស្នងការឆ្លើយយ៉ាងណាចំពោះករណីរបស់ឯកមាននិងផានូទេ ព្រោះការងារអាទិភាពរបស់នាង គឺអ្នកផ្សេង....

វគ្គ នាំហង្សនារីរត់គេច

ឯកមានគួរណាស់តែយល់ថាខ្លួនមានសំណាងដែលមានហង្សនារីមករត់លូនជាមួយ។ គេពិតជារកឃើញភូមិអ្នកស្រុក តែជាកូនភូមិតូចមួយគឺតូចបំផុត គ្មានសូម្បីតែភ្លើងអគ្គិសនីសម្រាប់ប្រើប្រាស់និងគ្មានគេហដ្ឋានអ្វីរឹងមាំក្រៅតែពីប្រភេទខ្ទមបណ្តោះអាសន្នតូចៗ។

ប្រការដែល គួរឱ្យភ្ញាក់ផ្អើលបំផុតមួយគឺ នៅពីមុខខ្ទមតូចៗបីបួននោះ អ្នកដែលចេញមកស្វាគមន៍ពួកគេសុទ្ធតែជាមនុស្សប្រុស....?

កម្មករកាប់ឈើ ឬអ្វីផ្សេងបានជាពួកគេគ្មានប្រពន្ធកូនមកតាម?

បុរសប្រហែលជា៦ឬ៧នាក់ចេញមកបង្ហាញខ្លួនក្បែរភ្នក់ភ្លើង។ ប្រុសស្រីទាំងពីរក្នុងសម្លៀកបំពាក់បែបនេះហើយបើមិនចង់ឱ្យគេមើលទើបចម្លែក។

ចិត្តឯកមានបារម្ភបំផុតគឺសម្រស់របស់នាង «ផានូ»។

នៅពីក្រោយខ្នងនាយ ឯកមានដឹងថាស្រីអភិជនកំពុងគិតដូចគ្នាបានជាដៃនាងក្តាប់នាយកាន់តែណែន កាន់តែត្រជាក់។

ទីនេះ កណ្ដាលស្មសាន មានតែពួកមនុស្សប្រុសមិនដឹងប្រវត្តិ នាងស្អាតយ៉ាងនេះ ស្លៀកពាក់ទ្រង់គ្រឿងទៀត តើការគេចចេញមកពីពួកអ្នកបើកឡាននិងមកដល់ទីនេះមួយណាប្រសើរជាង?

«ពូៗ ខ្ញុំឈ្មោះមាន ! គេនេះជាភរិយាខ្ញុំ ! គេមានជំងឺធ្ងន់ គេចេញពីការបងប្អូនខ្ញុំជូនគេមករកពេទ្យខ្មែរបុរាណ ពួកខ្ញុំវង្វេងផ្លូវត្រូវពួកចោរយករបស់ទ្រព្យអស់!»

ពួកគេឈានចូលមកកាន់តែកៀក ជាមួយពន្លឺកែវភ្នែកភ្លឺព្រាកៗ សម្លឹងមកនាងតូចលើសមុន។

នាងទំនងជាអោនគេចពីភ្នែកពួកគេបានជាបុរសទទួលអារម្មណ៍ថា បបូរមាត់តូចស្រីមកទើរលើស្មានាយ។

ទោះជាយ៉ាងណា ភាពតានតឹងថែមឡើងគឺនៅត្រង់ដែលពួកមនុស្សក្នុងព្រៃមិនស្រដីយ៉ាងណាសោះ។

ពួកគេគិតតែពីបន្តសម្លឹង....

សម្រាប់មនុស្សយើង ក្នុងកាលៈទេសៈពិបាកកម្រិតណាយើងតែងតែមានជម្រើស គឺយើងត្រូវតែបង្កើតជម្រើសសម្រាប់ខ្លួនឯង។

ឯកមាន មិនខ្វល់ទេ ប្រសិនបើគិតថា វាមិនមែនជារឿងងាយស្រួលក្នុងការស៊ីសង្វាក់ជាមួយនារីនេះ និយាយកុហកអ្នកស្រុក  ប៉ុន្តែនេះជាវេលាដែលការជ្រើសរើសថាសកម្មភាពណាមួយត្រឹមត្រូវឬខុស នៅឆ្ងាយពីហេតុនឹងផល។

«ជួយពួកខ្ញុំផង! ខ្ញុំរកផ្លូវទៅផ្ទះវិញមិនឃើញទេ!»

ផានូមានអារម្មណ៍ថាគ្រោះថ្នាក់នៅកៀកជាងមុន ទោះបីជានាងអាងលើឯកមានថាគេនឹងមិនបោះបង់ចោលនាងក្ដី។

«ប្រពន្ធឯងឈឺអី?»

«កើតឃ្លង់!»

ឮហើយកាលណាចង់តែច្រានមនុស្សប្រុសសំអុយម្នាក់នេះចេញឱ្យឆ្ងាយតាមដែលអាចធ្វើទៅបានហើយនាងមិនបានគិតដល់ទេថា ឯកមានចង់ឱ្យឈ្មោះជំងឺដែលគួរឱ្យខ្ពើមនេះ នឹងអាចការពារស្រីស្អាតពីការគិតប៉ុនប៉ងបំពានរាងកាយបាន។

សាជាថ្មី បុរសទាំងក្មេងចាស់ សម្លឹងមកលើនាង ធ្វើឱ្យនារីនេះ រឹតតែកើតសៅហ្មង។

ទឹកភ្នែកក្តៅឧណ្ហៗធ្លាក់មកលើស្មានាយស័ក្តិប្អូន ។

បេះដូងនាយធ្លាក់រាត់រាយព្រោះក្តីអាណិតធំជាងចិត្តលបលួចស្រលាញ់....

ដួងចន្ទពេលនេះវង្វេងមេឃហើយ នាងអាចរក្សារស្មីស្រទន់នោះបានដែរឬអត់អាស្រ័យលើបុរសម្នាក់ដែលនាងកំពុងតោងដៃ។

«កុំបាច់យំមីនាង! ចាំពូជួយ!»

សម្តីមួយឃ្លានេះប្រៀបដូចជាអំណោយរថយន្តមួយគ្រឿងទំនើបឱ្យអ្នកដែលកំពុងគ្មានសូម្បីតែកង់គ្រាន់និងជិះ។

ផានូឆ្លើយភ្លាមៈ

«ពូ! ខ្ញុំគ្រាន់តែចង់ដឹងផ្លូវវិលទៅភ្នំពេញវិញ !»

នាងអន្ទះសាណាស់គេដឹង។ គេមិនបន្ទោសតែចាប់ដៃនាងស្រាលៗចុះឡើងជាសញ្ញាឱ្យនាងទប់ចិត្ត។

«ចង់ចេញពីព្រៃទៅទាំងយប់មិនកើតទេ! តោះចូលរកកន្លែងសម្រាកអង្គុយនិយាយគ្នាឱ្យស្រួលសិន!»

អ្នកផ្សេងម្នាក់ទៀត លូកមាត់មកវិញ។

ភាពរាក់ទាក់របស់ពួកគេធ្វើឱ្យឯកមានចង់ទៅ តែនាងទាញគេមកវិញក្នុងភាពអន្ទះអន្ទែង។

«ផានូ! ចូលស្ទឹងតាមបទសិន!»

គេនិយាយខ្សឹបសែនខ្សឹបហើយនាងឆ្លើយមកវិញក៏រហ័សសែនរហ័សៈ

«ខ្ញុំចង់ទៅផ្ទះ!»

ឯកមានដាក់ដៃរបស់គេមួយទៀតទៅលើប្រអប់ដៃនាង ព្រោះគេដឹងថានារីនេះភ័យត្រជាក់ដៃជើងអស់ហើយ។

«ចង់ដូចគ្នា ផ្ទះគង់តែទៅទេ តែឆ្លងផុតយប់នេះសិន! ឈប់កញ្ជ្រោលពួ? ប្រយ័ត្នមានបញ្ហា! នៅស្ងៀមៗចាំខាងណោះដោះស្រាយ!»

នាងនៅស្ងៀមមែន។ អ្វីគ្រប់យ៉ាងដែលស្មុគស្មាញបែរជា អាចទ្រាំទ្របាន ព្រោះពួកអ្នកស្រុកលើកគ្រែមួយចេញមកតែម្ដងពេលឃើញស្រីតូចមិនព្រមចូលទៅក្នុងជម្រករបស់ពួកគេ។

«អង្គុយមកក្មួយ!»

ឯកមានងាកមើលមុខនាងហើយមិចភ្នែក។

គេលែងដៃនាងហើយអង្គុយតាមសម្ដីអ្នកស្រុក។ នាងនៅឈរក្បែរៗគេ រហូតដល់គេទាញឱ្យអង្គុយចុះមក។

បុរសដែលអ្នកទាំងពីរជួបកាលពីដំបូង ឈប់ក្បែរគ្រែហើយភ្នែកគាត់ងើយមើលទៅលើមេឃ។ អ្នកទាំងពីរអាចនឹងមិនដឹងទេ ថាគាត់កំពុងគិតអ្វី តែអ្នកស្រុកដែលនៅជុំវិញនេះ ដឹង ពីអត្ថន័យរបស់គាត់។

គាត់ងាកមកនិយាយទាំងញញឹមៈ

«មួយយប់នេះអត់ភ្លៀងទេ! ពីរនាក់ក្មួយសម្រាន្តនេះបាន!»

«ខ្ញុំចង់សុំប្រើទូរសព្ទ មានអ្នកណាមានទូរសព្ទទេ?»

ឯកមានសួរហើយនាងបើកភ្នែកគ្រលួងទន្ទឹងរង់ចាំចម្លើយ។

បុរសម្នាក់ដេកនៅក្បែរភ្នក់ភ្លើងឆ្លើយមកក្នុងសព្ទសំឡេងស្អកស្អាះ

«អត់មានសេវាទេក្មួយ! គ្មានភ្លើងអគ្គិសនីប្រើផង!ទាល់តែនៅភូមិ!»

នាងអង្គុយចុះតិចៗក្បែរឯកមានហើយក្រពាត់ដៃសម្លឹងទិដ្ឋភាពជុំវិញខ្លួន។ នាយHacker

គិតថាប្រាកដជានារីនេះមិនដែលស្រមៃពីការមកនៅទីនេះរំលងរាត្រីជាមួយប៉ូលិសឋានៈតូចដូចនាយឡើយ។

បុរសម្នាក់យកកញ្ច្រែងផ្លែចេកចេញមកក្នុងនោះមានផ្លែដទៃពីរបីទៀតដែលឯកមានមិនចាប់អារម្មណ៍។ គេលូកយកចេកមកបកបរិភោគធ្វើឱ្យនាងតាមសម្លឹង។ គេមានអាការៈដូចជាឃ្លានខ្លាំងណាស់ តែសម្លឹងឃើញភ្នែកគេ នាងបែរជាយល់ខ្លួនឯងថា hacker នេះជាមនុស្សពេញដោយបញ្ញា ។ គេគ្រាន់តែយកចិត្តពួកអ្នកស្រុកតែប៉ុណ្ណោះ។

គេស្រាប់តែហុចផ្លែផលាមួយទៀតមកឱ្យនាង។

«កុំឱ្យខូចក្រពះ!»

នាយនិយាយតិចៗទាំងសើចស្រស់ដាក់ស្រីស្អាត។

ខ្យល់ចាប់ផ្តើមបក់បំប៉ើងលើទងស្មៅ និងបណ្តាចុងព្រៃព្រឹក្សាដូចចិត្តធីតាអភិជនដែលកំពុងរងរង្គោះ ដោយភាពឯកកោ ភិតភ័យនិងមិនច្បាស់លាស់អំពីជោគវាសនារបស់ខ្លួន។

«អត់ឃ្លានទេឯកមាន!»

នាងនិយាយរំអុកតិចៗ ធ្វើឱ្យនាយហួសចិត្ត។

«ខ្ញុំដឹងនាងស្គាល់ឈ្មោះខ្ញុំហើយអ្នកនាង! មេត្តាមិនបាច់និយាយបានដែរអត់?»

ឮគេថាដូច្នេះ នារីហាក់យល់ការណ៍។ ផានូបន្ទូរដង្ហើមមកវិញ ហើយលូកដៃទទួលយក។

ខ្យល់បក់បន្ថែមបន្តិចបន្តួចទៀតបង្កជាសូរសំឡេង។

នារីក្រឡេកសម្លឹងចុះឡើងហើយស្រែកវាស់ភ្លាត់សំឡេង។

ឯកមានចំហមាត់ព្រោះមិនដែលឮនាងស្រែកឮយ៉ាងនេះ.....

ឃើញប៉ូលិសនេះសម្លឹងនាងហាក់ហួសចិត្ត ស្រីស្អាតលើកម្រាមចង្អុលទៅចំហៀងខាងស្តាំដៃគេ។

ឯកមានងៀងភ្នែកងាកទៅ។គេងាកទៅខ្វាច់ព្រោះតែពស់ថ្លាន់ធំមួយ កំពុងអើតកវែងមួយហត្ថមនុស្សចាស់ ពីក្នុងទ្រុងចេញមកក្រៅ។

ស្ថានភាពសត្វល្មូននេះទំនងជាអាចលូនចេញពីក្នុងមកក្រៅបានឱ្យតែវាបង្រួមខ្លួនតែបន្តិចទៀត។

នាងព្រិចភ្នែកបិទហើយអោនមកតោងស្មានាយជាប់។

«ពស់សោះហ្នឹង!ខ្លាចអី!»

«ពស់ហ្នឹងហើយខ្ញុំខ្លាច!»

នាងនិយាយតបទាំងក្តៅចិត្ត។គេសើចខឹកៗជាមួយពួកអ្នកភូមិ ធ្វើឱ្យនាងកាន់តែតវ៉ាះ

«ពស់មិនខ្លាចទៅខ្លាចអីវិញ?»

«ខ្ញុំចង់និយាយថា វាពស់មែនតែវានៅក្នុងទ្រុង ឃើញនៅ? វានៅក្នុងទ្រុង! មើលម្តងទៀតមើល៍ វាចេញមកម៉េចបាន?»

«ខ្ញុំមិនចង់មើលទេ! នៅក្នុងទ្រុងក៏ដោយ វាគ្មានសុវត្ថិភាពទេ !»

ដោយស្ងៀមស្ងាត់គេក្រោកឡើងម្តងទៀតហើយអង្គុយដូរកន្លែងជាមួយនាង។

«មកនៅខាងណេះមក ! លែងខ្លាចហើយ!?»

ផានូឃើញពួកប្រុសទាំងនោះនាំគ្នាសម្លឹងមើលមកអាការៈរបស់នាង ប៉ុន្តែនារីធ្វើពើជាមិនឃើញនិងមិនខ្វី រាក់ទាក់អីទាំងអស់។

«អាកាសធាតុល្អម៉េះ?»

ឯកមាននិយាយ ប៉ុន្តែនាងមិនទទួលអារម្មណ៍ថាល្អត្រង់ណាសោះ។

«នៅកន្លែងនេះគ្មានគ្រូព្យាបាលឃ្លង់ទេ! មានតែនៅភូមិថ្មី ចម្ងាយប្រមាណជា៦គីឡូ! ស្អែកឡើងអាចក្រោកទៅពីព្រឹកបាន»

ពូម្នាក់និយាយគ្រលរមកពីខាងឆ្វេងដៃ ។

នាងងាកទៅសម្លឹងគាត់។ ស្រីស្អាតប្រទះឃើញបុរសចំណាស់សម្លឹងមកនាងដោយអាណិតអាសូរ។

«ចាំពូទៅដាក់ដាំបាយ!»

«អ្ហូ! អត់អីទេ! កុំបាច់រំខាន! ពួកខ្ញុំ ពួកខ្ញុំញ៉ាំតែផ្លែឈើនេះក៏ ....ក៏បាន!»

នាងប្រញាប់បកចេកមកទំពា ក្រោមកែវភ្នែកហួសចិត្តរបស់ឯកមាន។ នាងខ្មើមរអើមទីនេះ នាងខ្លាចពេកឡើងអស់ឃ្លាន គេដឹងចិត្ត។

មិនទាន់អីផងនាងនិយាយទៀតៈ

«យប់ហើយ ពូនាំគ្នាសម្រាន្តវិញចុះ! ពួកខ្ញុំសុំដើរលេងជុំវិញនេះបន្តិចបានអត់?»

ចាស់ៗឆ្លើយតបវិញៈ

«បានចេញទៅត្បូងនោះ វាលធំស្រលះ មេឃជិតភ្លៀងក្លីស្រួលដើរទេ! តែកុំទៅជើងអី ថ្មើរណោះខ្លាចសត្វចេញ!»

នាងភ័យញ័រក្នុងចិត្តព្រោះឮពាក្យ«សត្វ» តែដៃម្ខាងទាញនាយស័ក្តិប្អូនឱ្យក្រោកឡើងមកជាមួយទាល់តែបាន។ ឯកមានដឹងថានារីនេះ បបួលចេញមកច្បាស់ជាមានរឿងសម្ងាត់ចង់រអ៊ូដាក់នាយពិតណាស់។

គេក្រោកឡើងដោយយកចេកមួយចំហៀងស្និតមកជាមួយផង។

វាលនៅទិសខាងត្បូង ពិតជាមានសភាពស្រលះល្អ ដូចពាក្យម្ចាស់ស្រុកទើបនឹងប្រាប់។

វាហាក់ដូចជាអតីតដីស្រែដែលគេលែងធ្វើហើយកករឹងក្លាយជាវាលស្មៅដ៏ធំ មានភាពងាយស្រួលធ្វើដំណើរ។ ដើមឈើរវេរាំជាមួយកម្លាំងខ្យល់ អមជាមួយសម្រែកសត្វរាត្រីចរនារដូវវស្សា។

«ពួកគេអាចកុហកយើងបងឯងត្រូវដឹង!»

នាងខ្សឹបតិចៗកៀកនឹងត្រចៀកបុរសនេះ។

ឯកមានសំងំស្ដាប់ ផានូនិយាយបន្ថែមៈ

«ពីកន្លែងយើងបែកគ្នាពីបងឈុនរាជ មកដល់នេះមិនឆ្ងាយអីប៉ុន្មានទេ! យើងមានរឿងអីនៅច្រើនគីឡូពីផ្ទះអ្នកភូមិ! បើថានេះ យើងរកច្រកចេញទៅវិញខ្លួនឯងទៅ!»

«ចេញតាមណា?»

គេសួរនាងខ្លី ធ្វើឱ្យស្រីស្អាតទ័ល។ នាងទីទើរមុនពេលវាចាតបៈ

«យើងរកមើលទៅ! គិតឡើងវិញទៅ! យើងជិះមកពីភ្នំពេញតាមណា ហើយផ្លូវណាដែលយើងទើបនឹងចូលមកនេះយើងទៅតាមច្រកហ្នឹងវិញ! ខ្ញុំគិតថា វាមិនឆ្ងាយដូចដែលគេកំពុងប្រាប់ទេឯកមាន!»

គេសម្លឹងនាងម៉ក់ៗព្រោះហួសចិត្ត។ នេះកុំតែនាងជាមនុស្សស្រីកុំអីត្រូវឯកមានថាឱ្យចាស់ដៃមិនខាន។

«បានកត់សំគាល់អត់ថារត់មកប៉ុន្មានស្រែ?»

គេនិយាយខ្សឹបៗហើយផ្ដោតទៅក្នុងកែវភ្នែកខ្មៅក្រឹបរបស់នាង។

«អត់ដឹងទេ! តែ.....នែ៎ បងឯងក៏ចេះថាដែរHacker ......យើងរត់មក មិនមែនហោះមកទេ! តើរយៈពេលប៉ុណ្ណឹងរត់បានប៉ុណ្ណាទៅ? ច្រើនណាស់ប៉ុន្មានគីឡូហ្នឹង! នៅមិននៅ.....»

គេលូកដៃពីក្រោយខ្ទប់មាត់នាងហើយខ្សឹបៈ

«ឈប់ហៅខ្ញុំHacker បើមិនចង់ឱ្យយើងមានបញ្ហា! ទីពីរបើទោះយើងរកឃើញផ្លូវត្រឡប់ទៅកន្លែងមុនវិញ ច្បាស់អត់ថាពួកនោះវាមិននៅចាំស្ទាក់ផ្លូវយើង?»

នាងនៅស្ងៀម។ តាមពិតមកពីប្រអប់ដៃនាយធំពេក នាងនិយាយអ្វីលែងចេញ។ គេខ្សឹបមកបន្ថែមគឺមាត់ក្បែរគុម្ពត្រចៀកនាងតែម្ដងៈ

«កុំ ឆោតល្ងង់មានៈខុសរឿង! បើផ្លូវនៅជិតនេះមែនយើងក៏ត្រូវចាំព្រឹកសិនដែរ!»

គេថាហើយ អោនសម្លឹងនាងដែលនៅស្ងៀម មុនពេលសម្រេចចិត្តថា បន្ធូរដៃលែងចេញបិទមាត់ ចប្រែតរបស់ កូនស្រីអ្នកមាន។

ឆ្ងល់ថាហេតុអ្វីបានជាលែងដៃហើយ នាងនៅតែមិនព្រនិយាយ?

តាមពិតនាងកំពុងផ្ទៀងស្ដាប់អ្វីម្យ៉ាង។ ពេលគេអោនទៅ នាងលើកម្រាមដៃស៊ីញ៉ូនាយឱ្យស្ងាត់។

«ពូ! ឃើញស្រីម្នាក់ប្រុសម្នាក់ រត់មកដល់នេះទេ?»

សូរសំឡេងលាន់មកល្ងើយៗតាមខ្យល់។ បេះដូងឯកមាន រលេះ ដាច់ដោច។ សង្គ្រាមតស៊ូនាំស្រីស្អាតទៅផ្ទះនៅមិនទាន់ចប់នៅឡើយ ក្បាលនាងក្រោមផែនទ្រូងបុរសនេះញ័រភិតភ័យ។

«គ្មានចម្លើយ!»

គេខ្សឹបតិចៗដាក់នាងតែស្រីស្អាតឆ្លើយវិញ  តិចៗ៖

«អត់ទេ! ប្រហែលមកពីឆ្ងាយពេកខ្យល់អត់បក់មកយើងស្ដាប់មិនឮ!»

ភាគទី៣៤

ផ្ទៀងយ៉ាងណាក៏មិនឮអ្នកស្រុកឆ្លើយថាយ៉ាងណាទាំងអស់។

ឯកមានរេសម្លឹងផ្លូវហើយស្វែងរកគោលដៅលាក់ខ្លួន។

«.... តែកុំទៅជើងអី ថ្មើរណេះខ្លាចសត្វចេញ!»

គេនឹកឃើញពាក្យដែលអ្នកស្រុកទើបនឹងប្រាប់ហើយងាកមើលរំពៃទៅទិសខាងជើង។

នាងដឹងហើយថាគេគិតបែបណា តែផានូប្រឹងរក្សាស្ងៀមស្ងាត់មិននិយាយរហូតដល់បុរសនេះទាញដៃនាងឱ្យរត់ទៅតាម។

«ឯកមាន! បងឯងចាំអត់? អ្នកស្រុកមិនឱ្យយើងទៅខាងជើងទេ!»

«អ៊ីចឹងគេក៏ហាមមិនឱ្យពួកនោះមកដូចគ្នា!»

គេឆ្លើយប្រញាប់ហើយរត់បន្ត ធ្វើឱ្យស្រីស្អាតភ្លេចអស់សភាពជើងដែលកំពុងឈឺចាប់ដោយការដាច់កកិត។

«ហើយបងឯងគិតថាកន្លែងគ្រោះថ្នាក់គឺជាសុវត្ថិភាព ប៉ុន្តែខ្ញុំខ្លាចណាស់ ខ្ញុំមិនចង់ជួបទេពស់ថ្លាន់!»

គេបន្ទោសតិចៗ៖

«គាត់ថាសត្វអាចចេញ! តែមិនមែនពស់ទេ!»

«សត្វអីក៏ដោយ!»

នាងរអ៊ូមាយាទាំងលាយឡំនូវភាពភ័យខ្លាចក្នុងរលកសំឡេង ។

«ខ្ញុំនៅតែប្រាប់ខ្លួនឯងថា ពួកនោះមិនអាចរកយើងឃើញដាច់ខាត!»

ឯកមាន និយាយឱ្យនារីនេះផ្ចង់មកលើពួកមនុស្សអាក្រក់ ជាជាងភ័យខ្លាចចំពោះទីស្មសាន ខាងមុខ។ ដៃនាងនៅក្នុងប្រអប់ដៃនាយចាប់ផ្ដើម ត្រជាក់ឡើងៗ ។ គេដឹងថា អារម្មណ៍នាង កំពុងវិលទៅរកអតីតកាលដែលថា ហេតុអីខ្លួនត្រូវរត់មកហើយហេតុអ្វីបានជាពួកនោះតាមរក។

ភ្លាមៗនោះឯកមានដកដង្ហើមធំ ហើយនិយាយបង្កើនទឹកចិត្តៈ

«យើងទៅផ្ទះវិញតាមផ្លូវនេះ»។

«ប្រាកដអត់?»

នាងសួរមកញ័រភ័យៗ។

អ្នកទាំងពីរ អាចមើលឃើញផ្លូវលំមួយនិង មែកឈើដ៏ធំៗ ដែលដុះទេរប្រេបជាស្រមោលខ្មៅ អមមាត់ព្រៃ។

រឿងមួយដែល បញ្ឈប់ការសន្ទនាពីរនាក់គឺស្នូរជើងមនុស្សធ្ងន់ៗលាន់មកពីចម្ងាយ.... ប៉ុន្តែវា មិនឮឆ្ងាយពេកទេ ព្រោះនេះជាពេលយប់ជ្រៅ។

«ប្រយ័ត្ន!»

ឯកមានទាញនាងចាកចេញពីផ្លូវទៅកំបាំងខ្លួនក្រោមស្រមោលខ្មៅនៃរុក្ខាពេលរាត្រី។

មនុស្សប្រុសម្នាក់នាំមុខដោយពន្លឺពិលហើយបង្ហាញខ្លួននៅភាគខាងត្បូងគឺទីវាលដែលពួកគេ ទើបនឹងគេចចេញមកមុននេះ។

«អ្ហ៎! ពីរនាក់?»

គាត់ហៅស្រាលៗ ។

គាត់មិនមែនមកតែឯងទេ ថែមទាំងមានបណ្ដើរកង់មួយមកផង។

ស្ថានភាពគាត់ដូចជាមិនបាននាំអ្នកណាមកតាមទេ។

គាត់ហៅហើយហៅទៀតរហូតដល់ឯកមានបម្រុងក្រោកចេញតែត្រូវនាងទាញមកវិញ ដោយគ្រវីក្បាលហាមមិនឱ្យគេចេញទៅ។

«ខ្ញុំគ្មានឃើញអ្នកផ្សេងទេ! គាត់ដូចជាកំពុងរកយើង!»

គេខ្សឹបបានត្រឹមតែប៉ុន្មានម៉ាត់នេះ ស្រាប់តែនាងចង្អុលឱ្យគេសម្លឹងតាម។

ឯកមានបែរទៅកាន់ទីនោះសាជាថ្មី គេឃើញអ្នកដែលកំពុងកាន់ពិលឡើងជិះកង់តម្រង់មកទីនេះជាមួយពន្លឺពិលដ៏ខ្សោយរបស់គេ។

«ពួកឯងចេញមក ពួយកពិលមកឱ្យ!»

គ្មានអ្នកណាមកតាមពីក្រោយបុរសនោះទេ។សំឡេងបុរសនេះក៏ពុំមែនជាអ្នកដែលពួកគេបានឃើញពីដំបូងដែរ តែអាចថាជាអ្នកណាម្នាក់នៅក្នុងចំណោមអ្នកដែលរស់នៅជុំវិញភ្នក់ភ្លើងមុននេះ។

អារម្មណ៍មួយប្រាប់ឯកមានថា បុរសនេះដូចជាគ្មានបំណងអ្វីអាក្រក់នោះឡើយ ប៉ុន្តែដៃស្រីស្អាតទាញជាយអាវគេជាប់ធ្វើឱ្យគេមិនអាចចេញបានដោយងាយស្រួលឡើយ។

«លែងដៃ គាត់ទំនងគ្មានគិតអាក្រក់អីលើយើងទេ!»

«បងឯងប្រាកដអត់?»

«កុំសួរដដែលៗ! យើងត្រូវការពិលនោះ! ចាំហ្នឹងហើយ! ខ្ញុំចេញម្នាក់ឯង!»

នាងទទួលស្គាល់នូវពាក្យដែលថា «យើងត្រូវការពិលនោះ!» ម្លោះហើយផានូលែងដៃឯកមានសន្សឹមៗ ។ បុរសក្រោកចេញពីក្រោយគល់ឈើល្មមពេលអ្នកកាន់ពិលមកឈប់ចម្ងាយប្រមាណ៥ម៉ែត្រពីគ្នា។

ឯកមានមិនមែនបង្ហាញខ្លួនតែឯងទេ នារីអភិជនក៏ចេញមកឈរពីក្រោយខ្នងនាយដូចគ្នា។

«ពួកក្មួយឯងនៅទៀតមិនបានទេ! មានគេមកសួររកអម្បាញ់មិញ!»

គាត់និយាយខ្សឹបប្រាប់ពេលដែលចូលដល់កៀកគ្នា។

ផានូអរភើតដែលបុរសនេះពិតជាមកក្នុងបំណងល្អ ដូចស្មាន ប៉ុន្តែនាងបុកពោះភ័យមិនដឹងថាអ្នកណាដែលសម្រុកតាមរកនាងដល់ទីនេះ។

«ពួកវានៅឯណា?»

ឯកមានខ្សឹបសួរតិចៗ។ បុរសចំណាស់មិនឆ្លើយ ដៃគាត់ហុចរបស់ម្យ៉ាងមកឱ្យនាយស័ក្តិបួន ដែលផានូមើលទៅមិនដឹងថាជាអ្វីឱ្យប្រាកដទេ ព្រោះទីនេះងងឹតស្រពិចស្រពិលហើយគាត់ក៏មិនចាំងពិលមកលើបាតដៃទៀត។

មានតែឯកមានប៉ុណ្ណោះដឹងថា វាជាទូរសព្ទប្រភេទថោកដែលកសិករនិយមមានប្រើ។

«វាគ្មានសេវាទេម្តុំនេះ! តែចេញដល់ភូមិគេ ក្មួយឯងសាកតេមើល!»

សភាពរបស់គាត់ចង់ប្រាប់ឱ្យប្រុសស្រីទាំងទ្វេរត់ពិតប្រាកដហើយ។

ខាងប៉ូលិសឆាប់យល់ការណ៍តែនាងនៅរងើរងើ។ បុរសចំណាស់ហុចពិលមកឱ្យហើយខ្សឹបផ្តាំ៖

«ជិះទៅត្រង់បាន២០០ម បត់ស្តាំកុំទៅឆ្វេង!»

គេង៉េមង៉ាមសម្លឹងដៃចង្កូតដែលគាត់ហុចមកឱ្យ។

«មិនត្រឹមពិលទូរសព្ទ ថែមទាំងឱ្យកង់ទៀត?»

ចិត្តនាយស័ក្តិបួនសែនរំភើប។ ប្រសិនបើមេឃភ្លឺវិញ អ្នកផងប្រាកដជាឃើញនាយរលីងរលោង។

បុរសនោះនិយាយមកបន្ថែមហាក់ប្រញាប់ប្រញាល់៖

«ពេលឃើញបង្គោលភ្លើង សសៀរតាមហ្នឹងរហូតទៅ! សម្គាល់រកមើលប្រភពពន្លឺភ្លើងពីចម្ងាយ បើជិតដល់ផ្លូវចូលភូមិមុខតែឃើញពន្លឺហើយ! ពួកខ្ញុំមិនបានឱ្យដំណឹងពិតដល់ពួកនោះទេ»

គាត់និយាយស្ដីដូចជាមនុស្សចេះដឹងធ្វើការរាជការហើយប្រកបដោយសមានចិត្ត។ ប្រុសស្រីទាំងទ្វេទទួលយករបស់ជំនួយដោយរំភើបចិត្តនិងដោយគ្មានការសង្ស័យ។ គេស៊កកូនទូរសព្ទ

ទៅក្នុងហោប៉ៅ ហើយអោនកាយគោរពបុរសនោះ ដែលសូម្បីតែមុខគាត់ក៏មិនអាចចំណាំស្គាល់។

គាត់បោយដៃបណ្ដេញឱ្យពួកគេប្រញាប់ចេញដំណើរ ។

ឯកមានស៊ីញ៉ូឱ្យនាងឡើងកង់ហើយក៏ដឹកស្រីស្អាតបកក្រោយចូលទៅកាន់ទីងងឹត។

«កាន់ពិលបញ្ចាំងផ្លូវឱ្យជាប់!»

គេបញ្ជានាងទាំងស្រីស្អាតធ្វើតាមដោយឥតតវ៉ាយ៉ាងណាឡើយ។

ក្នុងចិត្តឯកមានប្រហែលជានារីនេះថ្មីកជាមួយ ការបោះជុំរុំសប្បាយៗ ប៉ុន្តែនាងមិនដែលស្គាល់រសជាតិរត់កាត់ព្រៃស្ងាត់គ្មានពន្លឺ ដៃជើងរបួសហើយពោះក៏គ្មានបាយទឹកដូច្នេះទេ។

ពួកគេចាប់ផ្ដើមផ្សងព្រេងសាជាថ្មី តែពេលនេះគ្រាន់បើជាងមុនដែលមានពិលមកជាមួយ ហើយមិនមែនរត់ទេ គឺមានកង់ជិះ។

គ្មានអ្នកណានិយាយស្ដីអ្វីទាំងអស់ ព្រោះម្នាក់ៗស្ថិតក្នុងសភាពប្រុងជើងការហើយគិតជានិច្ចពីសមាសភាពអ្នកដែលលុកលុយចូលក្នុងភូមិតូចអម្បាញ់មិញដើម្បីសួររកខ្លួន។

«កន្លែងនេះមិនឆ្ងាយពីភ្នំពេញទេ ខ្ញុំដឹង!»

ផានូនិយាយប៉ប៉ាច់ឡើងវិញ ព្រោះនាងមិនអាចអត់ធន់បាននឹងកំសួលសេចក្ដីចង់ដឹង។ នាងចង់ដឹងចិត្តបុរសនេះថា តើ គេកំពុងគិតអ្វី ហើយគេសង្ឃឹមប៉ុណ្ណាក្នុងការនាំនាងទៅដល់ផ្ទះវិញ។

ទោះយ៉ាងណា គេមានកង់ហើយ នាងនៅតែមានសង្ឃឹមច្រើនជាងកាលដែលពឹងលើជើងមួយគូដើម្បីរត់។

«ពូមិញចិត្តល្អណាស់! ចាំយើងសងកង់គាត់វិញ!»

នៅតែមិនឃើញគេមាត់ក គិតពីជិះបន្តទៅមុខ ស្រីស្អាតរអ៊ូ៖

«នៅស្ងៀមធ្វើអី និយាយអីខ្លះមក ស្ងាត់ណាស់!»

«បើថាខ្លាចណាស់អោបចង្កេះមក!»

នាងលូកដៃមកតោងចង្កេះនាយមែន ក៏មានអត្ថន័យសារភាពថានាងពិតជាខ្លាចដូចដែលគេគិត។

«កំពុងគិតថាពួកវានោះជាអ្នកណា? ហេតុអីវាតាមមករកយើង?»

គេនិយាយតិចៗប្រណាំងលុបពីលើស្នូរច្រវាក់កង់។

នាងតបមកវិញបន្ទាន់៖

«អ្វីយ គិតច្រើនធ្វើអី ការងាររបស់ប៉ូលិសសោះហ្នឹង!»

នាងហាក់នឹកឃើញមកវិញទើបនិយាយកែពាក្យ៖

«រត់ចុះឡើងយូរពេក ភ្លេចគិតថា បងឯងជាប៉ូលិស!»

គេងៀងភ្នែកមកមើលនារីនេះដែលពេលខ្លះនាងនិយាយស្ដីស្មើកូនក្មេងមិនដឹងក្ដី។ ឃើញសភាពរបស់នាង ឯកមានហាក់ចង់ផុសចិត្តដៀមដាមឌឺដងលេង៖

«ឈប់ចង់ឬនៅអាពិធីឆ្លួតយក៍អីហ្នឹង?»

ស្រីស្អាតទើបនឹងចាប់អារម្មណ៍ថាបុរសនេះសម្ដីមហាអាក្រក់។

នាងនៅស្ងៀមទុកឱ្យគេបន្តថា៖

«អាណិតប្រធាននិស្សិតទាបកន្ទុលហ្នឹងម៉េះនៅមិននៅមានសិស្សប្អូនមហារពឹស!»

ទឹកភ្នែកទើបតែស្ងួតទេ តែពេលនេះនាងសើមប្រស្រីសាជាថ្មី ព្រោះនឹកដល់ឃុនរាជ។

ឯកមានក៏សំងំដូចគ្នាទំនងជានឹកឃើញអាណិតជនកាងសាលារកពាក្យនិយាយមិនត្រូវ។

«ហេតុអី ឡានប៉ះគ្នាលាន់ទ្រលោម អ្នកស្រុកមិញអត់ឮអីសោះ!»

នាងសួរតិចៗទាំងអស់កម្លាំងទន់ដៃជើង។

«យើងភៀសមកមិនតិចគីឡូទេ! សំឡេងមិនឮមកបានឆ្ងាយយ៉ាងនេះឯណា! សង្ឃឹមថាមានសមត្ថកិច្ចខេត្តណាអាចជួយឃុនរាជបានចុះ!»

ពួកគេងើបមុខតាមពន្លឺពិលក៏មើលឃើញចុងបញ្ចប់នៃផ្លូវ។ ពិតជាមានច្រកពីរតូចៗដូចផ្លូវរទេះ នាំទៅស្ដាំមួយនិងទៅឆ្វេងមួយទៀតពិតមែន។

«យើងមិនដឹងត្រូវជិះ រហូតដល់៦គីឡូម៉ែត្រមែនឬក៏អី??»

នារីសួរតិចៗ ។

«មានអីអស្ចារ្យមានកង់មួយទៅហើយ!»

គេរេចង្កូតបត់ទៅស្ដាំដៃ។ កូនខ្ទមមួយដាច់ដោចនៅប្របមាត់ផ្លូវ មានគ្រែឫស្សីតូចមួយ ដូចជាវាធ្លាប់ធ្វើជាកន្លែងសម្រាកសម្រាប់អ្នកដំណើរតែខានមានគេប្រើយូរហើយ។

«ខ្ញុំសុំអង្គុយសម្រាក!»

នាងនិយាយឡើងធ្វើឱ្យឯកមានសើចទាំងហត់គយូសហើយអោនមកក្រោយឆ្លើយ៖

«ងងឹតណាស់! មូសខាំ!»

«តែយើងមិនដឹងគោលដៅផងដើរដល់ពេលណាទៀត?»

នាងតវ៉ាទាំងសៅហ្មងបញ្ចេញមកតាមសូរសំឡេង ហើយចុចពិលឈប់បញ្ចាំង។

«តិចឈប់មែនឱ្យខ្លាចេញស៊ី! បើកពិលវិញឱ្យឆាប់!»

«មនុស្សសម្ដីអាក្រក់! មុននេះ បងឯងថាចង់ចេញពីព្រៃទៅទាំងយប់មិនកើតត្រូវ ចូលរកកន្លែងសម្រាកអង្គុយនិយាយគ្នាឱ្យស្រួលសិន! ស្រាប់តែពេលនេះ....»

គេមិនឆ្លើយ ឯនាងក៏នៅតែងរង៉ក់ តែដៃនារីនេះ ក៏នៅតែបញ្ចាំង ពិលសារមកវិញ។

ឯកមានឈប់កង់។

«ម៉េចហ្នឹង? មិញមានតូបឱ្យឈប់អត់ទេ? អាឡូវឈប់ធ្វើអី?»

នាងរអ៊ូ មិនទាន់ចប់ផង គេនិយាយខ្សឹបៗ៖

«បិទពិល!»

នាងចង់ខឹងទៀត តែងើបមុខមើលទៅឃើញបុរសនេះហាក់កំពុងផ្ទៀងស្ដាប់អ្វីម្យ៉ាងធ្វើឱ្យនាងងាកទៅផ្ទង់អារម្មណ៍ស្ដាប់ដែរ។

«ម៉ូតូម៉េចក៏បួនប្រាំដែរ!»

គេនិយាយខ្សឹបៗ ឯបេះដូងនាងបែរជាលោតដូចគេទូងស្គរ។

មិនដឹងហេតុផលអ្វី ស្រីប្រុសនេះកំពុងមានអារម្មណ៍ដូចគ្នាថា អ្នកដែលរោទ៍ម៉ូតូមកង៉ោងនោះមិនមែនជាមនុស្សល្អក៏មិនមែនជាអ្នកភូមិដែលជិះម៉ូតូកាត់តាមនេះជាធម្មតាដែរ។

បុរសបែរក្បាលកង់ចូលជ្រកក្រោមស្រមោលខ្មៅ។ គេពិតជារហ័សស្មើនឹងកម្លាំងម៉ូតូចំនួនប្រាំដែល សម្រុកចូលមករហ័សដូចផ្លេកបន្ទោរចាំងជះពន្លឺមកពីនាយ។

«កុំឱ្យវាឃើញយើងឱ្យសោះ!»

គេខ្សឹបប្រញាប់ទាំងដៃទាញស្រីស្អាតនឹងកង់ដកថយហើយថយទៀតមិនឈប់ឈររហូតដល់ប៉ះនឹងរបងព្រៃក្រាស់លែងអាចទៅណាបានទាំងអស់។

«ឱ្យតែវាចាំងភ្លើងមក ប្រាកដជារកយើងឃើញ!»

គេខ្សឹបទាំងលូកដៃទាញនាងមកអោបក្រៀកចង្កេះ។

ម៉ូតូបោលកាត់ទីនេះហួសទៅវឹងៗ ធ្វើឱ្យនាងសំងំឈឹងទាំងភ័យញ័រក្នុងដៃនាយ។

«ពួកវាអាចនឹងបកមកវិញ!»

គេនិយាយតិចៗ ស្រាប់តែនាងតវ៉ាភ្លាមៈ

«ម៉េចបងឯងដឹងថាជាពួកវា?»

«គ្មានអ្នកណាមកកាត់ណោះថ្មើរណោះហើយជិះម៉ូតូរបៀបហ្នឹងទេ!»

«ហើយម៉េចបងឯងដឹងថា ពួកវាបកមកវិញ?»

បុរសមិនឆ្លើយហើយភ្នែកគេផ្ដោតតែទៅលើគោលដៅទ្រូងផ្លូវ។

ម៉ូតូក្រោយគេដែលទើបតែសម្រុកទៅ ពេលនេះបកត្រឡប់មកវិញមែន។ គេនោះបើកមកក៏ឈប់ត្រង់ចិញ្ចើមផ្លូវនៅចំពីមុខប្រុសស្រីទាំងទ្វេប្រមាណជា១០ម៉ែត្រដោយរេក្បាលម៉ូតូចាំងភ្លើងចុះឡើង។

«វាឃើញដានកង់យើង!»

ឯកមានខ្សឹបហើយរលះរលាំងទាញដៃស្រីស្រស់ឱ្យនាងដើរមកតាមហើយសសៀរគេចទាំងពីរប្រាណទៅខាងឆ្វេងដៃចោលកង់តែម្តង។